United Nations Trust Fund for Human Security

UNITED NATIONS CAMBODIA



© រដ្ឋបាលខេត្តព្រះសីហនុ

## ខ្លឹមសារសង្ខេប

# “ក្រុងព្រះសីហនុសម្រាប់យើងទាំងអស់គ្នា៖ ជំរុញការអភិវឌ្ឍទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន”

ខែតុលា ឆ្នាំ ២០២១

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

UN-HABITAT
FOR A BETTER URBAN FUTURE

## សហការរៀបចំដោយ

**អ្នករៀបរៀង៖**
មន្ត្រីកម្មវិធីអង្គការសហប្រជាជាតិសម្រាប់លំនៅឋានមនុស្សជាតិ
លោកស្រី អ៊ីលៀណា តូសកាណូ ទីប្រឹក្សាគម្រោងថ្នាក់អន្តរជាតិ
លោកស្រី ហាក់ ដាំណែត ទីប្រឹក្សាគម្រោងថ្នាក់ជាតិ

**អ្នកចូលរួមផ្តល់ទិន្នន័យ៖**
ក្រុមការងារទីក្រុងឆ្លាតវៃខេត្តព្រះសីហនុ
មន្ត្រីរដ្ឋបាលខេត្ត ក្រុង អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធដទៃទៀត

**ដៃគូរសហការ និងផ្តល់ទិន្នន័យបន្ថែម៖**
លោក គ្រីស្តុហ្វ ស្មីតស៍ មន្ត្រីការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធមនុស្សប្រចាំកម្ពុជា
វិទ្យាស្ថានស្រាវជ្រាវច្បាប់បរិស្ថានអាស៊ាន ( Asian Research Institute on Environmental Law )

**អ្នកត្រួតពិនិត្យ៖**
លោកស្រី ផូលីន ថាម៉េស៊ីស ប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា
ការិយាល័យអ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា

បោះពុម្ពផ្សាយក្រោមគម្រោង «ក្រុងព្រះសីហនុសម្រាប់យើងទាំងអស់គ្នា៖ ជម្រុញការអភិវឌ្ឍទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាប័ន» ដឹកនាំដោយការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធមនុស្ស និងកម្មវិធីអង្គការសហប្រជាជាតិសម្រាប់លំនៅឋានមនុស្សជាតិ ក្រោមការសម្របសម្រួលរបស់ការិយាល័យអ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។

ឧបត្ថម្ភដោយ៖ មូលនិធិសន្តិសុខមនុស្សជាតិ

# បុព្វកថា

ការយល់ដឹង និងចក្ខុវិស័យរួមនៃ«ទស្សនទានទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន សម្រាប់ទីក្រុងព្រះសីហនុ» គឺជាសមិទ្ធផលមួយដែលទទួលបានពីគម្រោង «ទីក្រុងព្រះសីហនុសម្រាប់យើងទាំងអស់គ្នា៖ ជម្រុញការអភិវឌ្ឍទីក្រុងឆ្លាតវៃប្រកបដោយភាពឆ្លាតវៃ និងបរិយាប័ន្ន»។ តាមរយៈកិច្ចពិគ្រោះយោបល់ដែលមានលក្ខណៈចូលរួមផ្តួចផ្តើមឡើងក្រុមអង្គការសហប្រជាជាតិ និងឯកឧត្តម គួច ចំរើន អភិបាលខេត្តព្រះសីហនុ កាលពីខែវិច្ឆិកា ឆ្នាំ២០១៩ ដែលក្នុងនោះមានបញ្ហាជាច្រើនត្រូវបានលើកយកមកពិភាក្សា តួយ៉ាងដូចជា នគរូបនីយកម្ម កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ប្រកបដោយបរិយាបន្ន។ ជាមួយនឹងការអភិវឌ្ឍន៍ដ៏ឆាប់រហ័សនៅក្នុងខេត្តជាប់មាត់សមុទ្រមួយនេះ ភាគីពាក់ព័ន្ធជាច្រើនបានយល់ស្របគ្នាទៅលើការយកចិត្តទុកដាក់យ៉ាងមុតមាំ ដើម្បីធ្វើយ៉ាងណាឲ្យទីក្រុង និងខេត្តព្រះសីហនុអាចអភិវឌ្ឍប្រកបដោយភាពឆ្លាតវៃ និរន្តរភាព និងបរិយាបន្ន។

សេចក្តីប្រាថ្នារួមគ្នារបស់យើងសម្រាប់អនុវត្តទស្សនាទានទីក្រុងឆ្លាតវៃក្នុងក្រុងព្រះសីហនុ គឺផ្អែកលើរបៀបវារៈសាកលឆ្នាំ២០៣០និងការសម្រេចឲ្យបាននូវគោលដៅនៃការអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។ ខណៈដែលគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី11 សំដៅធានាឲ្យបាននូវ "ទីក្រុង និងលំនៅឋានដែលមានសុវត្ថិភាព ភាពធន់ និរន្តរភាព និងបរិយាបន្ន" គឺជាគោលដៅចំបងក្នុងទស្សនទាន ទីក្រុងឆ្លាតវៃ គោលដៅផ្សេងទៀតដែលពាក់ព័ន្ធនឹងភាពក្រីក្រ (SDG1) ភាពអត់ឃ្លាន (SDG2) សុខភាព (SDG3) សមភាពយេនឌ័រ (SDG5) វិសមភាព (SDG10) ទឹក (SDG6 &14) ការប្រែប្រួលអាកាសធាតុ (SDG13) និងដី (SDG15) ក៏ត្រូវតែបញ្ចូលទៅក្នុងក្របខ័ណ្ឌទីក្រុងឆ្លាតវៃផងដែរ។ បន្ថែមលើនេះ ការផ្សារភ្ជាប់ទីក្រុងឆ្លាតវៃទៅនឹង SDGs តែមួយមុខ គឺនៅមិនទាន់គ្រប់គ្រាន់នោះទេ ពីព្រោះគ្មានទីក្រុងណាមួយអាចត្រូវបានចាត់ទុកថាជាទីក្រុង"ឆ្លាតវៃ"នោះឡើយប្រសិនការអភិវឌ្ឍន៍ទីក្រុងនោះមិនបានគិតគូរ និងរក្សាបាននូវផលប្រយោជន៍សម្រាប់ប្រជាជនក្រីក្រ ព្រមទាំងក្រុមប្រជាពលរដ្ឋ និងសហគមន៍ដែលងាយរងគ្រោះ។

ដើម្បីក្លាយជាទីក្រុងឆ្លាតវៃដ៏ពិតប្រាកដ ទីក្រុងព្រះសីហនុត្រូវតែអនុលោមតាមផែនការមេ និងរួមបញ្ចូលនូវស្តង់ដារអន្តរជាតិ ព្រមទាំងគោលការណ៍ណែនាំនានាទាក់ទងនឹងលំនៅឋាន ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ការការពារបរិស្ថាន ការត្រៀមលក្ខណៈឆ្លើយតបនឹងគ្រោះមហន្តរាយ ការបណ្តេញចេញ និងការផ្លាស់ទីលំនៅដោយបង្ខំ។ នេះមានន័យថា ការអភិវឌ្ឍន៍ទីក្រុងប្រកបដោយបរិយាបន្ន និងនិរន្តរភាពត្រូវធានាឲ្យបាននូវសិទ្ធិក្នុងការចូលរួម និងសិទ្ធិទទួលបានព័ត៌មាន ការលើកកម្ពស់សមភាពយេនឌ័រ និងការគោរពសិទ្ធិមនុស្សទាក់ទងនឹងបញ្ហាដីធ្លី និងលំនៅឋានសម្រាប់មនុស្សគ្រប់រូប។ ក្របខ័ណ្ឌនៃគម្រោង ទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន បានច្របាច់បញ្ចូលនូវអភិក្រមសន្តិសុខមនុស្សជាតិដែលជាដំណោះស្រាយមួយសម្រាប់ទីក្រុងព្រះសីហនុ និងបំពេញតម្រូវការរបស់ប្រជាជនខ្លួន។

នៅក្រោមជំនួយឧបត្ថម្ភរបស់មូលនិធិសន្តិសុខមនុស្សជាតិ (Human Security Trust Fund) អង្គការសហប្រជាជាតិបានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារទីក្រុងឆ្លាតវៃ និងភាគីពាក់ព័ន្ធជាច្រើននៅក្នុងខេត្តព្រះសីហនុ ដើម្បីកំណត់អំពីតម្រូវការរបស់ពួកគេ និងផ្អែកលើអាទិភាពរបស់ពួកគេ សម្រាប់ ជំរុញការរៀបចំគោលនយោបាយ និងវិធានការរួមគ្នា។ យើងជឿជាក់ថា តាមរយៈធាតុចូលពីភាគីពាក់ព័ន្ធទាំងអស់ និងផ្អែកលើអភិក្រមសន្តិសុខមនុស្ស

ជាតិសម្រាប់ការអភិវឌ្ឍន៍ យើងអាចធ្វើឲ្យជីវភាពរស់នៅរបស់ប្រជាជនក្នុងទីក្រុងព្រះសីហនុមានការផ្លាស់ប្តូរ។ ការប្តេជ្ញាចិត្តរបស់យើង គឺដើម្បីធានាថា យើងអាចដោះស្រាយរួមគ្នានូវបញ្ហាការផាត់ចេញពីសង្គម និងការកាត់បន្ថយនូវភាពក្រីក្រ។ជាមួយនឹងការប្តេជ្ញាចិត្តនេះយើងនឹងរួមគ្នាពង្រឹងនូវទំនាក់ទំនងរវាងសន្តិភាព និងសន្តិសុខ ការអភិវឌ្ឍន៍ និងសិទ្ធិមនុស្ស ដែលចំណុចទាំងអស់នេះនឹងជួយរួមចំណែកអភិវឌ្ឍន៍ទីក្រុងព្រះសីហនុឆ្ពោះទៅរកភាពឆ្លាតវៃ និរន្តរភាព និងបរិយាបន្នភាព។

ក្នុងនាមអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមការងារទីក្រុងឆ្លាតវៃខេត្តព្រះសីហនុ រដ្ឋបាលខេត្តព្រះសីហនុ អាជ្ញាធរក្រុង និងភាគីពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានទាំងអស់ ដែលបានចូលរួម និងបានផ្តល់នូវវិភាគទានដ៏មានតំលៃនៅក្នុងដំណើរការរៀបចំរួមគ្នាស្តីពី ទស្សនទានទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្នសម្រាប់ទីក្រុងព្រះសីហនុ។ យើងនឹងបន្តឲ្យមាននិរន្តភាពក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីអនុវត្តន៍នូវទស្សនៈវិស័យរួមរបស់យើង។



**ផូលីន ថាម៉េស៊ីស**

ប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា

អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា

# មាតិកា


**បុព្វកថា** ........ ១

**១. សេចក្តីផ្តើម** ........ ៥

**២. ការត្រៀមខ្លួនសម្រាប់ការរៀបចំទស្សនទានទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន** ........ ៦

២.១ ទស្សនៈរបស់ភាគីពាក់ព័ន្ធក្នុងស្រុកអំពីទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន ........ ៦

២.២ ស្ថានភាពសន្តិសុខមនុស្សនៅក្រុងព្រះសីហនុ ដោយផ្អែកលើក្របខ័ណ្ឌសន្តិសុខមនុស្សរបស់អង្គការសហប្រជាជាតិ ........ ៧

២.៣ មេរៀនដែលទទួលបានពីករណីសិក្សា ស្តីពីទីក្រុងឆ្លាតវៃជាសកល ........ ៩

២.៤ ការធ្វើមូលធនកម្ម និងពង្រីកវិសាលភាពឧបករណ៍ឌីជីថលដែលមានស្រាប់ ដែលបង្កើតឡើងដោយ UN-Habitat ........ ៩

**៣. ទស្សនទានទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន សម្រាប់ក្រុងព្រះសីហនុ** ........ ១១

៣.១ វិសាលភាព និងគោលការណ៍ណែនាំ ........ ១១

៣.២ និយមន័យនៃទស្សនទានទីក្រុងឆ្លាតវៃប្រកបដោយនិរន្តភាព និងបរិយាបន្ន សម្រាប់ក្រុងព្រះសីហនុ ........ ១២

៣.៣. ក្រុងព្រះសីហនុសម្រាប់យើងទាំងអស់គ្នា៖ ផែនការសកម្មភាពទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តភាព និងបរិយាបន្ន ........ ១២

៣.៣.១ សសរស្តម្ភទី១៖ ផែនការឆ្លាតវៃ ដែលផ្តោតលើមនុស្ស និងការគ្រប់គ្រងតាមប្រព័ន្ធអេឡិចត្រូនិកតាមរយៈការចូលរួមឌីជីថល ប្រកបដោយភាពច្នៃប្រឌិត ........ ១២

៣.៣.២ សសរស្តម្ភទី ២៖ សេវាកម្មឆ្លាតវៃតាមរយៈទិន្នន័យ និងព័ត៌មានដែលមានប្រភពពីមហាជន ........ ១៣

៣.៣.៣ សសរស្តម្ភទី ៣៖ ការផ្តល់អំណាចឌីជីថលដើម្បីកាត់បន្ថយគន្លាតឌីជីថល និងលើកកម្ពស់សិទ្ធិមនុស្ស ........ ១៣

៣.៣ អនុសាសន៍យុទ្ធសាស្ត្រសន្តិសុខមនុស្សផ្តោតលើក្របខ័ណ្ឌទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្នសម្រាប់ក្រុងព្រះសីហនុ ........ ១៤

**៤. គំនិតផ្តួចផ្តើមឆ្លាតវៃទាំង១៣ ប្រកបដោយនិរន្តរភាព និងបរិយាបន្នសម្រាប់ក្រុងព្រះសីហនុ** ........ ១៦

៤.១. គំនិតផ្តួចផ្តើម ១.១. វេទិកាក្រុងព្រះសីហនុឆ្លាតវៃ តាមរយៈការចូលរួមអេឡិចត្រូនិក ........ ១៦

៤.២. គំនិតផ្តួចផ្តើម ១.២. វេទិកាអភិបាលកិច្ចអេឡិចត្រូនិក សម្រាប់ប្រជាពលរដ្ឋ ........ ១៧

៤.៣. គំនិតផ្តួចផ្តើម ១.៣. មជ្ឈមណ្ឌលសហគមន៍ឆ្លាតវៃ ........ ១៧

៤.៤. គំនិតផ្តួចផ្តើម ១.៤. ការធ្វើផែនការទីក្រុងឆ្លាតវៃសម្រាប់យុវជន ........ ១៨

៤.៥. គំនិតផ្តួចផ្តើម ២.១. ផែនទីបរិស្ថាន (ការគ្រប់គ្រងសំណល់, ទឹកជំនន់...) តាមរយៈព័ត៌មានដែលមានប្រភពពីមហាជន តាមប្រព័ន្ធឌីជីថល ........ ១៨

៤.៦. គំនិតផ្តួចផ្តើម ២.២. ដំណោះស្រាយឆ្លាតវៃសម្រាប់ប្រជាជនចំណាកស្រុក ........ ១៩

៤.៧. គំនិតផ្តួចផ្តើម ២.៣. កសិកម្ម និងស្បៀងអាហារឆ្លាតវៃ ........ ១៩

៤.៨. គំនិតផ្តួចផ្តើម ២.៤ ដំណោះស្រាយឆ្លាតវៃ សម្រាប់លំនៅឋាន និងការកាន់កាប់ដីធ្លី ........ ២០

៤.៩. គំនិតផ្តួចផ្តើម ២.៥. ទីក្រុងប្រកបដោយសុវត្ថិភាព ........ ២១

៤.១០. គំនិតផ្តួចផ្តើម ២.៦. ការថែទាំសុខភាពសម្រាប់សហគមន៍ ........ ២១

៤.១១. គំនិតផ្តួចផ្តើម ២.៧. ប្រព័ន្ធសេដ្ឋកិច្ចឆ្លាតវៃ ប្រកបដោយបរិយាបន្ន ........ ២២

៤.១២. គំនិតផ្តួចផ្តើម ៣.១. តំបន់សេវាអ៊ីនធើណែតឥតគិតថ្លៃក្នុងទីក្រុង និងជនបទ ជាពិសេសសម្រាប់ប្រជាជនក្រីក្រ និងក្រុមដែលមិនមានឱកាសទទួលបានសេវាកម្មអ៊ីនធើណែត ........ ២២

៤.១៣. គំនិតផ្តួចផ្តើម ៣.២. កម្មវិធីបណ្តុះបណ្តាលអចិន្ត្រៃយ៍ អំពីចំណេះដឹងកុំព្យូទ័រ និងបច្ចេកវិទ្យាសម្រាប់ប្រជាពលរដ្ឋ ជាពិសេសយុវជន តាមរយៈ «ទូតទីក្រុងឌីជីថល» ........ ២៣

**៥. គន្លឹះសំខាន់ៗសម្រាប់ការអនុវត្ត “ ទស្សនទានទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន នៅក្រុងព្រះសីហនុ”** ........ ២៤

**៦. សន្និដ្ឋាន និងអនុសាសន៍** ........ ២៧

# ១. សេចក្តីផ្តើម

«ទស្សនទានទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន» គឺជាលទ្ធផលនៃគម្រោង «ក្រុងព្រះសីហនុសម្រាប់យើងទាំងអស់គ្នា៖ ជំរុញការអភិវឌ្ឍទីក្រុងឆ្លាតវៃប្រកបដោយនិរន្តរភាព និងបរិយាបន្ន» ដែលបានផ្តួចផ្តើមឡើងដោយការិយាល័យសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាដឹកនាំដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) សហការជាមួយកម្មវិធីអង្គការសហប្រជាជាតិសម្រាប់លំនៅឋានមនុស្សជាតិ (UN-Habitat) ក្រោមជំនួយថវិការបស់មូលនិធិអង្គការ សហប្រជាជាតិសម្រាប់ទ្រទ្រង់សន្តិសុខមនុស្សជាតិ។ គម្រោងនេះ បានធ្វើការសិក្សាវាយតម្លៃយ៉ាងទូលំទូលាយ ដើម្បីផ្តួចផ្តើមការរៀបចំទស្សនទានក្រុងព្រះសីហនុឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន ដោយអនុវត្តតាមវិធីសាស្ត្រសន្តិសុខមនុស្ស និងបង្កប់នូវទស្សនវិស័យស្នូល ជាសកលរបស់ UN-Habitat គឺ «ទីក្រុង ឆ្លាតវៃ ដោយយកកត្តាមនុស្សជាចំបង»។

«ទស្សនទានទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន» ត្រូវបានបង្កើតឡើងតាមរយៈវិធីសាស្ត្រដែលផ្តោតលើមនុស្ស ផ្អែកលើយេនឌ័រ និងគិតគូរដល់សិទ្ធិមនុស្ស។ វាត្រូវបានបង្កើតឡើងយ៉ាងម្ចត់ចត់តាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) និងរបៀបវារៈទីក្រុងថ្មី ដោយផ្តោតលើឱកាសឆ្លាតវៃ ជាក់ស្តែង ដើម្បីឱ្យសហគមន៍ និងក្រុមប្រជាជនងាយរងគ្រោះ និងមិនសូវទទួលបានការយកចិត្តទុកដាក់ឱ្យទទួលបានឱកាសចូលរួមក្នុងដំណើរការឌីជីថលនីយកម្ម ព្រោះ «គ្មានទីក្រុងណាត្រូវបានចាត់ទុកថាជា ទីក្រុង “ឆ្លាតវៃ” នោះទេ ប្រសិនបើទីក្រុងនោះមិនយកចិត្តទុកដាក់ដល់ផលប្រយោជន៍របស់ពលរដ្ឋក្រីក្រ» ដែលនេះត្រូវបានលើកឡើងដោយលោកស្រី Pauline Tamesis ប្រធានអង្គការសហប្រជាជាតិ ប្រចាំប្រទេសកម្ពុជា ក្នុងកិច្ចប្រជុំជាមួយក្រុមការងាររៀបចំយុទ្ធសាស្ត្រទីក្រុងឆ្លាតវៃក្រុងព្រះសីហនុ កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ ។

“ទស្សនទានទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន” ត្រូវបានបង្កើតឡើងដោយយោងតាមលទ្ធផលនៃការវិភាគអំពីគម្លាតនៃការអភិវឌ្ឍបច្ចុប្បន្ន បញ្ហាប្រឈមនានាដែលកំពុងកើតឡើងក្នុងទីក្រុង ព្រមទាំងក្របខ័ណ្ឌគោលនយោបាយដែលមានស្រាប់ និងមេរៀនដែលទទួលបានពីករណីសិក្សា ស្តីពីទីក្រុង ឆ្លាតវៃនានាជាសកល។ ទិន្នន័យ និងព័ត៌មានដែលទទួលបានតាមរយៈការស្រាវជ្រាវឯកសារ ការសម្ភាស ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងអនុសាសន៍ដែលទទួលពីការសិក្សាវាយតម្លៃសន្តិសុខមនុស្សជាតិ នៅក្រុងព្រះសីហនុផ្ទាល់ ត្រូវបានប្រើប្រាស់ដើម្បីកំណត់គំនិតផ្តួចផ្តើមចំនួន១៣ ប្រកបដោយភាពឆ្លាតវៃ និរន្តរភាព និងបរិយាបន្ន នៃទស្សនទានទីក្រុងឆ្លាតវៃក្រុងព្រះសីហនុ។

# ២. ការត្រៀមខ្លួនសម្រាប់ការរៀបចំទស្សនទានទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន

## ២.១ ទស្សនៈរបស់ភាគីពាក់ព័ន្ធក្នុងស្រុកអំពីទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន

ក្រោមគម្រោង «ក្រុងព្រះសីហនុសម្រាប់យើងអស់គ្នា» ក្រុមការងាររៀបចំយុទ្ធសាស្ត្រទីក្រុងឆ្លាតវៃក្រុងព្រះសីហនុត្រូវបានបង្កើតឡើង ដែលមានសមាសភាពចូលរួមពីមន្ទីរអង្គភាពពាក់ព័ន្ធសំខាន់ៗ អាជ្ញាធរ មូលដ្ឋាន ស្ថាប័នឯកជន អង្គការសង្គមស៊ីវិល និងទីភ្នាក់ងារអង្គការសហប្រជាជាតិ។ ក្រុមការងារនេះបានចូលរួម ក្នុងដំណើរការកំណត់ទស្សនទានទីក្រុងឆ្លាតវៃ សម្រាប់ក្រុងព្រះសីហនុ តាមរយៈវិធីសាស្ត្រនានារួមមានកិច្ចប្រជុំពិគ្រោះយោបល់និងការសម្ភាសផងដែរ។

ការប្រជុំពិគ្រោះយោបល់ដែលមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធចំនួនពីរ និងកិច្ចសម្ភាសន៍ភាគីពាក់ព័ន្ធ ដាច់ដោយឡែក ត្រូវបានរៀបចំឡើងដើម្បីប្រមូលព័ត៌មានទាក់ទងនឹងគម្លាតនៃការអភិវឌ្ឍនាពេលបច្ចុប្បន្ន និងការពិភាក្សារៀបចំទស្សនវិស័យ ស្តីពីក្រុងព្រះសីហនុឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន ពីភាគីពាក់ព័ន្ធក្នុងស្រុក។

ទស្សនៈរបស់ភាគីពាក់ព័ន្ធដែលប្រមូលបានក្នុងកិច្ចប្រជុំពិគ្រោះយោបល់ និងការសម្ភាសនោះមានដូច ខាងក្រោម៖

ទស្សនវិស័យរួម សម្រាប់ទីក្រុងឆ្លាតវៃនៃក្រុងព្រះសីហនុប្រកបដោយនិរន្តរភាព និងបរិយាបន្ន គឺ:

«ទីក្រុងឆ្លាតរបស់ក្រុងព្រះសីហនុ គឺជាទីក្រុងដែលមានភាគរបរិស្ថានជាតំបន់សេដ្ឋកិច្ចពហុបំណងជាមជ្ឈមណ្ឌលហិរញ្ញវត្ថុអាស៊ី និងជាកន្លែងដែលមនុស្សគ្រប់គ្នាចង់រស់នៅ»។

«ទីក្រុងឆ្លាតរបស់ក្រុងព្រះសីហនុ គឺជាទីក្រុងដែលផ្តល់នូវជីវភាពរស់នៅ ដែលបំពេញតម្រូវការរបស់ ប្រជាពលរដ្ឋ មានបរិស្ថានប្រកបដោយនិរន្តរភាព សន្តិសុខ និងសុវត្ថិភាពសាធារណៈ ប្រើប្រាស់ប្រព័ន្ធឌីជីថល និងបច្ចេកវិទ្យា ដើម្បីជំរុញសេដ្ឋកិច្ចពហុបំណង និងប្រសិទ្ធភាពអភិបាលកិច្ច ដើម្បីលើកកម្ពស់សុខ ដុមនីយកម្ម និងសុខុមាលភាពប្រជាជន»។

**បញ្ហាសំខាន់ៗលើកឡើងដោយភាគីពាក់ព័ន្ធ ដែលត្រូវដោះស្រាយតាមរយៈគំនិតផ្តួចផ្តើមនានា នៃទស្សនទានទីក្រុងឆ្លាតវៃ៖**

- តម្រូវការក្នុងការបង្កើតក្របខ័ណ្ឌអភិបាលកិច្ចអេឡិចត្រូនិកអចិន្ត្រៃយ៍ និងក្របខ័ណ្ឌដើម្បីលើក ទឹកចិត្តឱ្យមានការចូលរួមពីប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋានទាំងនៅក្នុងតំបន់ទីក្រុង និងជនបទ។
- បំណងប្រាថ្នាចង់ឱ្យមានកម្មវិធីបណ្តុះបណ្តាលអំពីការប្រើប្រាស់កុំព្យូទ័រ និងការចូលរួមក្នុងវិស័យអប់រំ ដើម្បីធ្វើការផ្លាស់ប្តូរទៅរកប្រព័ន្ធឌីជីថល។
- តម្រូវការកែលម្អបញ្ហាបរិស្ថាន និងដោះស្រាយបញ្ហាប្រឈមនានា ដូចជាការប្រមូលសំរាម និងទឹកជំនន់ក្នុងទីក្រុង។

**គំនិតផ្តួចផ្តើមអាទិភាពនានា សម្រាប់ក្រុងព្រះសីហនុឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្នៈ**

អាជ្ញាធរមូលដ្ឋាន និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសិក្ខាសាលា នៅខែមិថុនា និងខែកញ្ញា ឆ្នាំ២០២១ បានបង្ហាញទស្សនៈរួម ដោយជ្រើសយកគំនិតផ្តួចផ្តើមដែលផ្តោតលើ (១)មជ្ឈមណ្ឌលយុវជនឆ្លាតវៃ(២)កម្មវិធីបណ្តុះបណ្តាលកុំព្យូទ័រ និងបច្ចេកវិទ្យាអចិន្ត្រៃយ៍សម្រាប់ប្រជាពលរដ្ឋ (៣) ការកែលម្អការគ្រប់គ្រង សំណល់រឹង និងទឹកកខ្វក់នៅក្នុងទីក្រុង (៤) ការថែទាំសុខភាពឆ្លាតវៃ និង (៥) សន្តិសុខ និងសុវត្ថិភាព សាធារណៈ ជាអាទិភាពសម្រាប់ទស្សនទានទីក្រុងឆ្លាតវៃក្រុងព្រះសីហនុ។ លើសពីនេះ ពួកគេបានគូសបញ្ជាក់ថា បើគ្មានកម្មវិធីកសាងសមត្ថភាពសមស្របក្នុងចំណោមអង្គភាពសាធារណៈ និងប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ ពលរដ្ឋឆ្លាតវៃទេនោះ ទីក្រុងមិនអាចត្រូវបានគេរំពឹងថានឹងផ្លាស់ប្តូរទៅជា ទីក្រុងឆ្លាតវៃដែលមាននិរន្តភាព និងបរិយាបន្នបានទេ។

## ២.២ ស្ថានភាពសន្តិសុខមនុស្សនៅក្រុងព្រះសីហនុ ដោយផ្អែកលើក្របខ័ណ្ឌសន្តិសុខមនុស្សជាតិ របស់អង្គការសហប្រជាជាតិ

ការវាយតម្លៃសន្តិសុខមនុស្សត្រូវបានធ្វើឡើងដោយវិទ្យាស្ថាន ARIEL ក្នុងនាមជាទីប្រឹក្សារបស់អង្គការ OHCHR ដែលជាដៃគូសំខាន់បំផុតរបស់គម្រោង «ក្រុងព្រះសីហនុសម្រាប់យើងទាំង អស់គ្នា»។ ការវាយតម្លៃនេះ ត្រូវបានធ្វើឡើងដោយផ្អែកលើក្របខ័ណ្ឌសន្តិសុខមនុស្សជាតិរបស់អង្គការសហប្រជាជាតិ[១]ដែលកំណត់ប្រភេទសន្តិសុខមនុស្សចំនួន ៧ ប្រភេទ ដូចជា (១) សន្តិសុខសេដ្ឋកិច្ច (២) សន្តិសុខស្បៀង (៣) សន្តិសុខសុខភាព(៤) សន្តិសុខបរិស្ថាន (៥) សន្តិសុខផ្ទាល់ខ្លួន (៦) សន្តិសុខ កម្រិតសហគមន៍ និង (៧) ភាពជឿជាក់លើស្ថាប័ន។

ដោយផ្អែកលើស្ថានភាពបច្ចុប្បន្ននៃសន្តិសុខមនុស្ស និងក្របខ័ណ្ឌ «គម្រោងក្រុងព្រះសីហនុសម្រាប់យើងទាំងអស់គ្នា»ដែលបង្កប់នូវគោលគំនិតទីក្រុងឆ្លាតវៃប្រកបដោយនិរន្តរភាព និងបរិយាបន្ន មានអនុសាសន៍ យុទ្ធសាស្ត្រចំនួន១០ ត្រូវបានកំណត់ សម្រាប់គំរូក្រុងព្រះសីហនុឆ្លាតវៃ។ អនុសាសន៍ជាយុទ្ធសាស្ត្រទាំងនេះមានគោលបំណងបង្កើតធាតុផ្សំសំខាន់ៗនៃ "ភាពឆ្លាតវៃ" រួមជាមួយនិរន្តរភាព និងបរិយាបន្ន ដែលបំពេញ តម្រូវការក្នុងការលើកកម្ពស់ក្រុងព្រះសីហនុ។ អនុសាសន៍យុទ្ធសាស្ត្រទាំងនោះរួមមានៈ

១. ពង្រឹងស្វ័យភាពកាន់តែខ្ពស់សម្រាប់ការសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន និងមានការចូលរួមខ្ពស់ពីប្រជាពលរដ្ឋនៅក្នុងដំណើរការបង្កើតគោលនយោបាយមូលដ្ឋាន

២. ផ្តល់អំណាចដល់ការពិភាក្សារវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋ តាមរយៈវេទិកាចូលរួមតាមប្រព័ន្ធឌីជីថលឱ្យបានគ្រប់គ្រាន់ និងយន្តការទទួលបណ្តឹងតវ៉ានិងការដោះស្រាយប្រកបដោយប្រសិទ្ធិភាព

៣. ពង្រឹងការយល់ដឹងអំពីច្បាប់ សិទ្ធិ និងកាតព្វកិច្ចដែលមានចែងក្នុងច្បាប់

៤. សម្រេចបាននូវនិរន្តរភាពបរិស្ថាន និងស្តង់ដារគុណភាពជីវិតខ្ពស់

៥. សម្រេចបាននូវការអនុវត្ត និងការត្រៀមខ្លួនឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ប្រកបដោយ ប្រសិទ្ធភាព

៦. លើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីធុរកិច្ចដែលមានលក្ខណៈអំណោយផលដល់ភាពជាសហគ្រិន និងការធ្វើពិពិធកម្មសេដ្ឋកិច្ច

៧. ស្តារឡើងវិញនូវនិរន្តរភាព តាមរយៈការធ្វើឱ្យប្រសើរឡើងនូវស្វ័យភាពស្បៀងអាហារ

៨. ផ្តល់ជូនប្រជាពលរដ្ឋនូវសេវាថែទាំសុខភាពឱ្យបានគ្រប់គ្រាន់

៩. ផ្តល់ជូនប្រជាពលរដ្ឋទាំងអស់នូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភគ្រប់គ្រាន់

១០. ផ្តល់ជូនប្រជាពលរដ្ឋទាំងអស់នូវសន្តិសុខ និងសុវត្ថិភាពកាន់តែល្អប្រសើរ

---

១ https://www.un.org/humansecurity/wp-content/uploads/២០១៧/១០/h២.pdf

## រូបភាពទី ១៖ កត្តាដែលទាក់ទងនឹងបញ្ហាប្រឈមនៃសន្តិសុខមនុស្សដែលប្រជាពលរដ្ឋជួបប្រទះនៅក្រុងព្រះសីហនុ



## ២.៣ មេរៀនដែលទទួលបានពីករណីសិក្សាស្តីពីទីក្រុងឆ្លាតវៃជាសកល

ទន្ទឹមនឹងការពិគ្រោះយោបល់ ករណីសិក្សាជាសកលជាច្រើនត្រូវបានស្រាវជ្រាវយ៉ាងល្អិតល្អន់ ដើម្បី បំផុសគំនិត និងទទួលបានមេរៀនពីទីក្រុងដទៃទៀត ដែលលើកកម្ពស់យុទ្ធសាស្ត្រទីក្រុងឆ្លាតវៃ។ តាមរយៈ ការសម្ភាស និងការស្រាវជ្រាវឯកសារ ក្រុមការងារបានរៀបចំរបាយការណ៍លម្អិតមួយហៅថា "មេរៀនសង្ខេប ដែលទទួលបានពីករណីសិក្សាស្តីពីទីក្រុងឆ្លាតវៃដែលផ្តោតលើប្រជាពលរដ្ឋ"។ របាយការណ៍នេះ មានគោលបំណងបង្ហាញពីគំនិតរួមនៃទីក្រុងឆ្លាតវៃ ដែលផ្តោតលើប្រជាពលរដ្ឋ ជាមេរៀនពីទីក្រុងឆ្លាតវៃ ប្រកបដោយ បរិយាបន្ន និងដើម្បីកំណត់នូវផែនទីបង្ហាញពីវិធីសាស្ត្រ សម្រាប់ដំណើរការប្រមូលទិន្នន័យ និងព័ត៌មានជាក់លាក់ ដែលចាំបាច់សម្រាប់ការសហការរៀបចំទស្សនទានទីក្រុងឆ្លាតវៃ ជាមួយក្រុមការងាររៀបចំយុទ្ធសាស្ត្រទីក្រុងឆ្លាតវៃក្រុងព្រះសីហនុ។

ដំណើរការនៃការប្រមូលឯកសារ និងការវិភាគករណីសិក្សាទីក្រុងឆ្លាតវៃ ត្រូវបានធ្វើឡើងដោយផ្តោតសំខាន់លើសិទ្ធិមនុស្ស ដើម្បីធានាថាទស្សនៈ «មិនមានពលរដ្ឋណាម្នាក់ត្រូវបានគេទុកចោល» បានដាក់បញ្ចូល ទៅក្នុងស្នូលនៃទស្សនទានទីក្រុងឆ្លាតវៃសម្រាប់ក្រុងព្រះសីហនុ។

ការដាក់បញ្ចូលស្ត្រី និងក្មេងស្រី ព្រមទាំងក្រុមមនុស្សដែលទទួលបានការយកចិត្តទុកដាក់តិចតួចបំផុត រួមទាំងជនមានពិការភាព ក្នុងការរៀបចំទស្សនទានទីក្រុងឆ្លាតវៃ គឺជាគោលការណ៍សំខាន់ដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ទូទៅ និងប្រជាជនក្នុងមូលដ្ឋាន ដោយយកចិត្តទុកដាក់ជាពិសេសចំពោះក្រុមមនុស្សក្រីក្រ និងដែលងាយ រងគ្រោះ។

មេរៀនជាច្រើន ព្រមទាំងបទពិសោធន៍នៃការអនុវត្តល្អៗពីទីក្រុង ដែលគិតពីនិរន្តរភាព បរិយាបន្ន និងឆ្លាតវៃ ត្រូវបានបែងចែកជា៣ ក្រុម តាមប្រភេទនៃបទពិសោធន៍ត្រូវបានដកស្រង់យកជាសសរស្តម្ភចំនួនបីដែលទ្រទ្រង់ដល់គំនិតផ្តួចផ្តមទីក្រុងឆ្លាតវៃសម្រាប់ក្រុងព្រះសីហនុ៖

១. *វិធីសាស្ត្រឌីជីថលប្រកបដោយភាពច្នៃប្រឌិត នៃការចូលរួមរបស់ពលរដ្ឋ (យោងតាមបទពិសោធន៍ពីទីក្រុងបូឡូណា និងបាសេឡូណា)។*

២. *ការប្រមូលទិន្នន័យ ដើម្បីកែលម្អ សេវាកម្ម និងគ្រឿងបរិក្ខារទីក្រុង តាមរយៈប្រភពព័ត៌មានពីមហាជន តួយ៉ាងសម្រាប់ការកែលម្អមធ្យោបាយដឹកជញ្ជូនសាធារណៈ សុវត្ថិភាពនៅទីសាធារណៈ សម្រាប់ស្ត្រី និងក្មេងស្រី ការធ្វើឱ្យទីក្រុងប្រសើរឡើង និងការគ្រប់គ្រងបញ្ហាបរិស្ថាន (យោងតាមបទពិសោធន៍ពី ទីក្រុងណៃរ៉ូប៊ី ដេលី ហ្សាការតា និងប៉េកាំង)។*

៣. *ការកាត់បន្ថយគម្លាតឌីជីថល ដោយផ្តល់នូវវិធីសាស្ត្រសមស្របនៃការដាក់បញ្ចូលឌីជីថល (យោងតាមបទពិសោធន៍ពីទីក្រុងសេអ៊ូល និងចូហានណេសប៊ីក)។*

## ២.៤ ការធ្វើមូលធនកម្ម និងពង្រីកវិសាលភាពឧបករណ៍ឌីជីថលដែលមានស្រាប់ ដែលបង្កើតឡើងដោយ UN-Habitat

ទស្សនទានទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន បានពង្រីកវិសាលភាពនៃឧបករណ៍ ឌីជីថលដែលមានស្រាប់ ដែលបង្កើតឡើងដោយ UN-Habitat ក្នុងគោលបំណងបង្កើនកិច្ចសហ-ប្រតិបត្តិការ និងអនុវត្តបទពិសោធន៍ជោគជ័យមួយចំនួន ដែលបានសាកល្បងរួចនៅក្នុងក្រុងព្រះសីហនុ។

**ក្នុងនោះ រួមមាន៖**

- **គំនិតផ្តួចផ្តើមមួយប្លុកម្តងៗ[២] (Block by Block initiative)** ដែលមានគោលបំណងបង្កើនការ ចូលរួមរបស់សហគមន៍ក្នុងមូលដ្ឋាន ក្នុងការសហការរចនាតំបន់ទីក្រុង ដើម្បីធ្វើឱ្យប្រសើរឡើង និងបង្កើតឡើងវិញ តាមរយៈល្បែងកំសាន្តដោយប្រើវីដេអូហ្គេម

២ https://www.blockbyblock.org/

"Minecraft" ដែលត្រូវបាន ពិពណ៌នាដោយសាមញ្ញថាជា "LEGO និម្មិត"។

- **ប្រអប់ឧបករណ៍ទីក្រុងសម្រាប់ស្ត្រី**[៣] (**Her City Toolbox**) ជាវេទិកាឌីជីថល ដែលមានមូលដ្ឋានលើការលេងកំសាន្ត ដែលជំរុញការគិតឡើងវិញ និងរៀបចំផែនការទីក្រុង ដោយគិតគូរបញ្ហាពីយេនឌ័រ។
- **គំរូ STDM**[៤] (**Social Tenure Domain Model**) ជាឧបករណ៍គ្រប់គ្រងដីធ្លី សម្រាប់ជួយដល់ ជនក្រីក្រ សំដៅគាំទ្រដល់សហគមន៍មូលដ្ឋាន និងបុគ្គលម្នាក់ៗ ក្នុងការអភិវឌ្ឍឧបករណ៍គ្រប់គ្រង ដីធ្លី ដែលឆ្លើយតបនឹងបញ្ហាគម្លាតបច្ចេកទេសទាក់ទងនឹងដីដែលមិនបានចុះបញ្ជី និងការធ្វើឱ្យប្រសើរឡើងនូវតំបន់មិនទាន់រៀបរយ ការតាំងលំនៅបណ្ដោះអាសន្ន ព្រមទាំងការគ្រប់គ្រង ទីក្រុង និងជនបទ។




៣ https://hercity.unhabitat.org/

៤ https://stdm.gltn.net/

# ៣. ទស្សនទានទីក្រុងឆ្លាតវៃ ប្រកប ដោយនិរន្តរភាព និងបរិយាបន្ន សម្រាប់ក្រុងព្រះសីហនុ

## ៣.១ វិសាលភាព និងគោលការណ៍ណែនាំ

ទស្សនទានទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន ត្រូវបានបង្កើតឡើងដោយផ្អែកលើ របៀបវារៈនៃការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ ២០៣០ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព SDG ១១ ស្តីពីទីក្រុង និងសហគមន៍ប្រកបដោយនិរន្តរភាព ក៏ដូចជាគោលដៅអភិវឌ្ឍន៍ផ្សេងទៀត ដែលទាក់ទងនឹងភាព អត់ឃ្លាន ភាពក្រីក្រ វិសមភាព សុខភាព សមភាពយេនឌ័រ ដីធ្លី ទឹក និងការប្រែប្រួលអាកាសធាតុ។

វិសាលភាពនៃទស្សនទាននេះ នឹងជំរុញឱ្យមានការចូលរួមយ៉ាងសកម្ម នៅក្នុងក្រុងព្រះសីហនុ ដោយ បង្កើតសម្ព័ន្ធភាពថ្មីរវាងប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានតាមរយៈវិធីសាស្ត្រទីក្រុងឆ្លាតវៃ ដើម្បីផ្តល់នូវការរៀបចំផែនការទីក្រុង ការថែទាំសេវាកម្ម បរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធក្នុងទីក្រុងឱ្យមានលក្ខណៈល្អប្រសើរសម្រាប់មនុស្សគ្រប់រូប ដោយរួមបញ្ចូលទាំងក្រុមមនុស្សដែលងាយរងគ្រោះ និងអ្នកដែលទទួលបានការយក ចិត្តទុកដាក់តិចបំផុត ឱ្យទទួលបាននូវសុខភាពល្អ ខ្យល់ និងបរិយាកាសល្អ និងទឹកស្អាត សុវត្ថិភាពនៃការ គ្រប់គ្រងសំណល់ សន្តិសុខ និងសុវត្ថិភាព និងឱកាសអភិវឌ្ឍន៍ស្មើៗគ្នា។

គោលការណ៍សំខាន់ៗចំនួនបី ត្រូវបានយកមកប្រើដើម្បីបង្កើតទស្សនទានទីក្រុងឆ្លាតវៃនេះឡើងសំដៅជំរុញការអនុវត្តកម្មវិធីទីក្រុងឆ្លាតវៃ ប្រកបដោយភាពច្នៃប្រឌិត ដោយយកទស្សនៈ «មិនមានពលរដ្ឋណាម្នាក់ត្រូវបានគេទុកចោល» ជាស្នូល៖

១. **ទី១៖ វិធីសាស្ត្រទីក្រុងឆ្លាតវៃដែលផ្តោតលើប្រជាពលរដ្ឋ** ជាវិធីសាស្ត្រដែលយកតម្រូវការរបស់ប្រជា- ពលរដ្ឋដាក់នៅចំកណ្តាលនៃយុទ្ធសាស្ត្រទីក្រុងឆ្លាតវៃ។ វាផ្តោតសំខាន់លើមនុស្ស ហើយមិនមែនផ្តោត លើបច្ចេកវិទ្យាតែម៉្យាងព្រោះការផ្តោតសំខាន់លើបច្ចេកទេសតែមួយមុខ គឺមិនគ្រប់គ្រាន់ក្នុងការផ្តល់នូវ ដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត ដែលឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋឡើយ។ វិធីសាស្ត្រនេះ ជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ តាមរយៈវេទិកា និងមជ្ឈមណ្ឌលប្រជាពលរដ្ឋដែលប្រកបដោយភាពច្នៃប្រឌិត (innovative citizen laboratories and civic platforms) ដោយផ្តល់នូវសេវាកម្មអេឡិចត្រូនិកថ្មីៗ ដែលគាំទ្រដល់ប្រព័ន្ធដឹកជញ្ជូន ការផ្តល់លំនៅឋាន ការប្រមូល សំណល់/សំរាម ការផលិតស្បៀងអាហារ និងការដឹកជញ្ជូន និងកិច្ចការជាច្រើនទៀត។

២. **ទី២៖ ទស្សនទានសិទ្ធិមនុស្សសម្រាប់ទីក្រុងឆ្លាតវៃ** គឺជាទស្សនទានដែលឆ្លើយតបចំពោះគំនិតផ្តួច ផ្តើមទីក្រុងឆ្លាតវៃ ដែលសំដៅជំរុញបរិយាបន្ន និងធានាឱ្យបានថា គ្មាននរណាម្នាក់ ជាពិសេសប្រជាជនដែលក្រីក្រនៅក្រុងព្រះសីហនុ ត្រូវបានផ្តាច់ចេញពីដំណើរការនៃការផ្លាស់ប្តូរទៅរកការប្រើប្រាស់ឌីជីថលប្រកបដោយភាពច្នៃប្រឌិតនោះឡើយ។ វិធីសាស្ត្រនេះ ជួយឱ្យយើងរៀបចំគំនិតផ្តួចផ្តើមទីក្រុង ឆ្លាតវៃដែលធានាឱ្យប្រជាជនមូលដ្ឋានរស់នៅក្នុងសង្គមដោយស្មើភាព យុត្តិធម៌ និងសេចក្តីថ្លៃថ្នូរ ហើយទទួលបាន

អត្ថប្រយោជន៍ដូចៗគ្នាពីការផ្លាស់ប្តូរទៅរកឌីជីថល ។

៣. **ទី៣៖ ការផ្តោតសំខាន់លើ ក្មេងស្រី និងស្ត្រីសម្រាប់ទីក្រុងឆ្លាតវៃ** ជាទស្សនៈដែលមានគោលបំណង លើកកម្ពស់ការដាក់បញ្ចូលស្ត្រី និងក្មេងស្រីទៅក្នុង សង្គមបែបប្រជាធិបតេយ្យ ដោយប្រកាន់យក ទស្សនៈថា «បើយើងធ្វើផែនការទីក្រុងសម្រាប់ក្មេងស្រី វានឹងផ្តល់ផលសម្រាប់មនុស្សគ្រប់គ្នា» ដែលជាគោលគំនិតនៃចលនា «Urban Girls Movement» ដើម្បីដោះស្រាយគម្លាត យេនឌ័រ និងរក្សាការតភ្ជាប់ ព្រមទាំងឱកាសស្មើគ្នាសម្រាប់ស្ត្រីលើសកលលោកក្នុងការប្រើប្រព័ន្ធឌីជីថល។ វិធីសាស្ត្រនេះ ជំរុញការផ្លាស់ប្តូរគំរូក្នុងការធ្វើផែនការទីក្រុង ដោយផ្តោតលើតម្រូវការរបស់ស្ត្រី និងក្មេងស្រី និងដាក់បញ្ចូលពួកគេទៅក្នុងដំណើរការនៃការសម្រេចចិត្តដើម្បីលើកកម្ពស់សុខភាពសាធារណៈ និងអនាម័យ ឱ្យបានគ្រប់គ្រាន់ ការទទួលបានការអប់រំ ឱកាសការងារ ការដោះស្រាយការប្រែប្រួលអាកាសធាតុ និងការធានាសន្តិសុខសង្គម និងទីក្រុង។

## ៣.២ និយមន័យនៃទស្សនទានទីក្រុងឆ្លាតវៃប្រកបដោយនិរន្តរភាព និងបរិយាបន្ន សម្រាប់ក្រុងព្រះសីហនុ

ផ្អែកលើគោលការណ៍ ទីក្រុងឆ្លាតវៃដែលផ្តោតសំខាន់លើមនុស្ស ផ្តោតការយកចិត្តទុកដាក់លើស្ត្រី និងលើកម្ពស់ការគោរពសិទ្ធិមនុស្សព្រមទាំងឆ្លើយតបនឹងបំណងប្រាថ្នារបស់ក្រុមការងារនៅមូលដ្ឋាន និយមន័យ នៃទីក្រុងឆ្លាតវៃប្រកបដោយនិរន្តរភាព និងបរិយាបន្ន សម្រាប់ក្រុងព្រះសីហនុ ត្រូវបានកំណត់ដូចខាងក្រោម៖

*«ទីក្រុងឆ្លាតវៃ គឺជាទីក្រុងដែលជំរុញការផ្សារភ្ជាប់តាមទម្រង់ថ្មី រវាងប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន ដើម្បីបំពេញតម្រូវការប្រជាពលរដ្ឋ និងលើកកម្ពស់សិទ្ធិមនុស្ស ដោយមានផែនការ និងការអនុវត្តច្បាស់លាស់ ហើយផ្តល់សេវាកម្ម ព្រមទាំងបរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធល្អប្រសើរ ដើម្បីលើកកម្ពស់ បរិយាបន្ន យុត្តិធម៌ សមធម៌ និរន្តរភាព បរិស្ថាន ព្រមទាំងសន្តិសុខ និងសុវត្ថិភាពសាធារណៈ។»*

*«ទីក្រុងឆ្លាតវៃ ប្រើប្រាស់បច្ចេកវិទ្យា និងប្រព័ន្ធឌីជីថល ដើម្បីបង្កើនប្រសិទ្ធភាពអភិបាលកិច្ច និងសេដ្ឋកិច្ចពហុបំណង ប្រកបដោយបរិយាបន្ន និងនិរន្តរភាព ដើម្បីលើកកម្ពស់សុខដុមនីយកម្ម និងសុខុមាលភាពសម្រាប់ប្រជាជនគ្រប់ស្រទាប់វណ្ណៈ ជាពិសេសក្រុមប្រជាជនក្រីក្រ និងខ្វះឱកាស ទទួល បាននូវសុខភាពល្អ ខ្យល់ស្អាត ទឹកស្អាត ការគ្រប់គ្រងសំណល់ប្រកបដោយសុវត្ថិភាព សិទ្ធិកាន់កាប់ដីធ្លី និងលំនៅឋាន ព្រមទាំងឱកាសក្នុងការអភិវឌ្ឍស្មើៗគ្នា និងមិនទុកពលរដ្ឋណាម្នាក់ចោលឡើយ »។*

## ៣.៣. ក្រុងព្រះសីហនុសម្រាប់យើងទាំងអស់គ្នា៖ ផែនការសកម្មភាពទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តភាព និងបរិយាបន្ន

ផែនការសកម្មភាពទីក្រុងដែលមាននិរន្តភាព បរិយាបន្ន និងឆ្លាតវៃ ផ្តោតលើគំនិតផ្តួចផ្តើមឆ្លាតវៃជាច្រើន ដែលដាក់ប្រជាជននៅចំកណ្តាលនៃចក្ខុវិស័យទីក្រុងឆ្លាតវៃទាំងមូល។ វាផ្តល់ការយកចិត្តទុកដាក់ជាពិសេសដល់ក្រុមពលរដ្ឋក្រីក្រ ជនមានពិការភាព ស្ត្រី និងក្មេងស្រី ដើម្បីបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋនិងសហគមន៍ទាំងមូល លើកកម្ពស់អភិបាលកិច្ចអេឡិចត្រូនិក ធ្វើឱ្យប្រសើរឡើងនូវសេវាកម្ម និងបរិក្ខារមូលដ្ឋាន តាមរយៈ សកម្មភាពនិងព័ត៌មានដែលទទួលប្រភពពីសាធារណៈ ព្រមទាំងកាត់បន្ថយគម្លាតឌីជីថល និងគម្លាតយេនឌ័រ។

ដើម្បីសម្រេចគោលដៅនេះ ផែនការសកម្មភាពទីក្រុងឆ្លាតវៃប្រកបដោយនិរន្តរភាព និងបរិយាបន្ន ត្រូវបានរៀបចំឡើងដោយមានសសរស្តម្ភចំនួន៣ និងគំនិតផ្តួចផ្តើមមួយចំនួន នៅក្រោមសសរស្តម្ភនីមួយៗ។

### ៣.៣.១ សសរស្តម្ភទី១៖

**ផែនការឆ្លាតវៃ ដែលផ្តោតលើមនុស្ស និងការគ្រប់គ្រងតាមប្រព័ន្ធអេឡិចត្រូនិក តាមរយៈការចូលរួមឌីជីថលប្រកបដោយភាពច្នៃប្រឌិត**

យុទ្ធសាស្ត្រ ដែលស្ថិតនៅក្រោមសសរស្តម្ភនេះ មាន

គោលបំណងឆ្លើយតបទៅនឹងអនុសាសន៍ជា យុទ្ធសាស្ត្រស្តីពីសន្តិសុខមនុស្ស ដែលទាក់ទងនឹងការចូលរួមដោយវៃឆ្លាតរបស់សហគមន៍មូលដ្ឋានដោយ បញ្ចូលការចូលរួមពីប្រជាពលរដ្ឋក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ដោយដាក់បញ្ចូលស្ត្រី និងក្មេងស្រី ទៅក្នុងក្របខ័ណ្ឌចូលរួមអេឡិចត្រូនិក សម្រាប់ការគិតគូរឡើងវិញអំពីមុខងារទីក្រុងតាមរយៈការចូលរួមតាមប្រព័ន្ធវីដេអូ (online) និងចូលរួមដោយផ្ទាល់។ យុទ្ធសាស្ត្រលើកកម្ពស់ប្រព័ន្ធអភិបាលកិច្ចអេឡិចត្រូនិក ដែលមានតម្លាភាព និងសមភាព ដែលអាចឱ្យប្រជាពលរដ្ឋទទួលបានព័ត៌មាន និងបានដាក់បញ្ចូលទៅក្នុងការកំណត់ជីវភាពរស់នៅក្នុងទីក្រុង។

គំនិតផ្តួចផ្តើមចំនួន៤ ដែលមានគោលបំណងលើកកម្ពស់ការចូលរួមឆ្លាតវៃ ត្រូវបានកំណត់ដើម្បីគាំទ្រ ដល់សសរស្តម្ភទី១នេះ គឺ៖

- ***គំនិតផ្តួចផ្តើម*១.១.*វេទិកាឆ្លាតវៃសម្រាប់ក្រុងព្រះសីហនុតាមរយៈការចូលរួមអេឡិចត្រូនិក***
- ***គំនិតផ្តួចផ្តើម ១.២.*** *វេទិកាអភិបាលកិច្ចអេឡិចត្រូនិកសម្រាប់ប្រជាពលរដ្ឋ*
- ***គំនិតផ្តួចផ្តើម ១.៣.*** *មជ្ឈមណ្ឌលសហគមន៍ឆ្លាតវៃ*
- ***គំនិតផ្តួចផ្តើម១.៤.****ការធ្វើផែនការទីក្រុងឆ្លាតវៃសម្រាប់យុវជន*

## ៣.៣.២ សសរស្តម្ភទី ២៖

### សេវាកម្មឆ្លាតវៃតាមរយៈទិន្នន័យ និងព័ត៌មានដែលមានប្រភពពីមហាជន

សសរស្តម្ភនេះ គ្របដណ្តប់លើយុទ្ធសាស្ត្រ ដែលមានគោលបំណងប្រមូលព័ត៌មាន និងទិន្នន័យ ដែលមានប្រយោជន៍ ដើម្បីរៀបចំឡើងវិញនូវសេវាកម្មប្រជាពលរដ្ឋជាពិសេសផ្តោតលើស្ត្រី ក្រុមពលរដ្ឋក្រីក្រ និងជនមានពិការភាព តាមរយៈការសហការ និងការចូលរួមដោយផ្ទាល់ពីសហគមន៍មូលដ្ឋាន។ វាឆ្លើយតបទៅនឹងអនុសាសន៍យុទ្ធសាស្ត្រសន្តិសុខមនុស្សដែលទាក់ទងនឹងនិរន្តរភាពនិងបរិយាបន្ន។ គំនិតផ្តួចផ្តើមចំនួន៧ ដែលទ្រទ្រង់ សសរស្តម្ភទី២នេះ គឺ៖

គំនិតផ្តួចផ្តើម ២.១. ផែនទីបរិស្ថាន (ការគ្រប់គ្រងសំណល់ ទឹកជំនន់...) តាមរយៈព័ត៌មានដែលមានប្រភពពីមហាជនតាមប្រព័ន្ធឌីជីថល

- ***គំនិតផ្តួចផ្តើម ២.២.*** *ដំណោះស្រាយឆ្លាតវៃសម្រាប់ការធ្វើចំណាកស្រុក*
- ***គំនិតផ្តួចផ្តើម២.៣.****កសិកម្មនិងស្បៀងអាហារឆ្លាតវៃ*
- ***គំនិតផ្តួចផ្តើម ២.៤.*** *ដំណោះស្រាយឆ្លាតវៃសម្រាប់លំនៅឋាន និងការកាន់កាប់ដីធ្លី*
- ***គំនិតផ្តួចផ្តើម ២.៥.*** *ទីក្រុងដែលមានសុវត្ថិភាព*
- ***គំនិតផ្តួចផ្តើម ២.៦.*** *ការថែទាំសុខភាព សហគមន៍*
- ***គំនិតផ្តួចផ្តើម ២.៧.*** *ប្រព័ន្ធសេដ្ឋកិច្ចឆ្លាតវៃប្រកបដោយបរិយាបន្ន*

## ៣.៣.៣ សសរស្តម្ភទី ៣៖

### ការផ្តល់អំណាចឌីជីថលដើម្បីកាត់បន្ថយគន្លាតឌីជីថល និងលើកកម្ពស់សិទ្ធិមនុស្ស

យុទ្ធសាស្ត្រនៃសសរស្តម្ភនេះ មានគោលបំណងលើកកម្ពស់សិទ្ធិមនុស្ស និងក្របខ័ណ្ឌសន្តិសុខមនុស្ស ជាតិដោយផ្តល់ឱកាសស្មើៗគ្នាដល់ពលរដ្ឋគ្រប់រូប ដើម្បីទទួលបានអត្ថប្រយោជន៍ពីការផ្លាស់ប្តូរទៅកាន់ឌីជីថល តាមរយៈការលើកកម្ពស់ប្រព័ន្ធអប់រំ និងក្របខ័ណ្ឌពង្រឹងសមត្ថភាពឱ្យបានគ្រប់គ្រាន់ ដើម្បីលើកកម្ពស់ជំនាញ ប្រជាពលរដ្ឋក្នុងការប្រើប្រាស់បច្ចេកវិទ្យា។ គំនិតផ្តួចផ្តើមនៃសសរស្តម្ភទី៣នេះ ឆ្លើយតបទៅ នឹងអនុសាសន៍យុទ្ធសាស្ត្រសន្តិសុខមនុស្សដែលទាក់ទងនឹងបរិយាបន្ន។ គំនិតផ្តួចផ្តើមដែលគាំទ្រដល់សសរស្តម្ភនេះ មានដូចខាងក្រោម៖

- ***គំនិតផ្តួចផ្តើម៣.១.****តំបន់សេវាអ៊ីនធើណិតឥតគិតថ្លៃក្នុងទីក្រុង និងជាយក្រុង ជាពិសេសសម្រាប់ប្រជាជនក្រីក្រ និងក្រុមដែលមិនមានឱកាសទទួលបានសេវាកម្មអ៊ីនធើណែត។*
- ***គំនិតផ្តួចផ្តើម ៣.២.*** *កម្មវិធីបណ្តុះបណ្តាលកុំព្យូទ័រ និងបច្ចេកវិទ្យាអចិន្ត្រៃយ៍ តាមរយៈការបង្កើត«ទូតទីក្រុងឌីជីថល»។*

## ៣.៣ អនុសាសន៍យុទ្ធសាស្ត្រសន្តិសុខមនុស្សផ្តោតលើក្របខ័ណ្ឌទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្នសម្រាប់ក្រុងព្រះសីហនុ

| សសរស្តម្ភ នៃក្រុងព្រះសីហនុឆ្លាតវៃប្រកបដោយនិរន្តរភាពនិងបរិយាបន្ន | គំនិតផ្តួចផ្តើម/ផែនការសកម្មភាពដែលត្រូវលើកកម្ពស់ | អនុសាសន៍យុទ្ធសាស្ត្រសន្តិសុខមនុស្សដែលត្រូវគ្នា |
| --- | --- | --- |
| **សសរស្តម្ភទី ១៖** ការធ្វើផែនការឆ្លាតវៃ និង អភិបាលកិច្ចអេឡិចត្រូនិច ដោយមានការចូលរួមតាមប្រព័ន្ធឌីជីថលប្រកបដោយភាពច្នៃប្រឌិត | **គំនិតផ្តួចផ្តើម ១.១.** វេទិកាឆ្លាតវៃសម្រាប់ក្រុងព្រះសីហនុ តាមរយៈការចូលរួមអេឡិចត្រូនិក<br>**គំនិតផ្តួចផ្តើម ១.២.** វេទិកាអភិបាលកិច្ចអេឡិចត្រូនិកសម្រាប់ប្រជាពលរដ្ឋ<br>**គំនិតផ្តួចផ្តើម ១.៣.** មជ្ឈមណ្ឌលសហគមន៍ឆ្លាតវៃ<br>**គំនិតផ្តួចផ្តើម ១.៤.** ការធ្វើផែនការទីក្រុងឆ្លាតវៃសម្រាប់យុវជន | **ការលើកកម្ពស់ "ការចូលរួមឆ្លាតវៃ"**<br>១. ពង្រឹងស្វ័យភាពកាន់តែខ្ពស់សម្រាប់ការសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន និងមានការចូលរួមខ្ពស់ពីប្រជាពលរដ្ឋនៅក្នុងដំណើរការបង្កើតគោលនយោបាយកម្រិតមូលដ្ឋាន។<br>២. លើកកម្ពស់ការពិភាក្សារវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល ដោយបញ្ចូលការធ្វើវេទិកាឌីជីថលគ្រប់គ្រាន់ និងយន្តការ បណ្តឹងតវ៉ា/ការដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព។<br>៣. បង្កើនការយល់ដឹងអំពីច្បាប់ សិទ្ធិ និងកាតព្វកិច្ចដែលមានចែងក្នុងច្បាប់។ |
| **សសរស្តម្ភទី ២៖** សេវាកម្មឆ្លាតវៃតាមរយៈទិន្នន័យ និងព័ត៌មានដែលមានប្រភពពីមហាជន | **គំនិតផ្តួចផ្តើម ២.១.** ផែនទីបរិស្ថាន (ការគ្រប់គ្រងសំណល់, ទឹកជំនន់....) តាមរយៈព័ត៌មានដែលមានប្រភពពីមហាជនតាមប្រព័ន្ធឌីជីថលគំនិតផ្តួចផ្តើម **២.២.** ដំណោះស្រាយឆ្លាតវៃសម្រាប់ប្រជាជនចំណាកស្រុក<br>**គំនិតផ្តួចផ្តើម ២.៣.** កសិកម្ម និងស្បៀងអាហារឆ្លាតវៃ<br>**គំនិតផ្តួចផ្តើម ២.៤.** ដំណោះស្រាយឆ្លាតវៃសម្រាប់លំនៅឋាន និងការកាន់កាប់ដីធ្លី<br>**គំនិតផ្តួចផ្តើម ២.៥.** ទីក្រុងដែលមានសុវត្ថិភាព<br>**គំនិតផ្តួចផ្តើម ២.៦.** ការថែទាំសុខភាពសម្រាប់សហគមន៍<br>**គំនិតផ្តួចផ្តើម ២.៧.** ប្រព័ន្ធសេដ្ឋកិច្ចឆ្លាតវៃប្រកបដោយបរិយាបន្ន | **ការលើកកម្ពស់ "និរន្តរភាព និងបរិយាបន្ន"**<br>៤. សម្រេចបាននូវនិរន្តរភាពបរិស្ថាន និងស្តង់ដារគុណភាពជីវិតកាន់តែខ្ពស់។<br>៥. សម្រេចបាននូវការអនុវត្ត និងការត្រៀបចំពោះការប្រែប្រួលអាកាសធាតុឱ្យកាន់តែមានប្រសិទ្ធភាព។<br>៦. លើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីអាជីវកម្មដែលមានលក្ខណៈអំណោយផលដល់ភាពជាសហគ្រិន និងការធ្វើពិពិធកម្មសេដ្ឋកិច្ច។<br>៧. ស្តារឡើងវិញនូវនិរន្តរភាព តាមរយៈការធ្វើឱ្យប្រសើរឡើងនូវស្វ័យភាព ស្បៀងអាហារ។<br>៨. ផ្តល់ជូនប្រជាពលរដ្ឋនូវសេវាថែទាំសុខភាពឱ្យបានគ្រប់គ្រាន់។<br>៩. ផ្តល់ជូនប្រជាពលរដ្ឋទាំងអស់នូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភគ្រប់គ្រាន់។<br>១០. ផ្តល់ជូនប្រជាពលរដ្ឋទាំងអស់នូវសន្តិសុខ និងសុវត្ថិភាពកាន់តែល្អប្រសើរ។ |

| សសរស្តម្ភ នៃក្រុងព្រះសីហនុឆ្លាតវៃប្រកបដោយនិរន្តរភាព និងបរិយាបន្ន | គំនិតផ្តួចផ្តើម/ផែនការសកម្មភាព ដែលត្រូវលើកកម្ពស់ | អនុសាសន៍យុទ្ធសាស្ត្រសន្តិសុខមនុស្សដែលត្រូវគ្នា |
|---|---|---|
| **សសរស្តម្ភទី ៣៖** ការផ្តល់អំណាចឌីជីថលដើម្បីកាត់បន្ថយគម្លាតឌីជីថល និងលើកកម្ពស់សិទ្ធិមនុស្ស | **គំនិតផ្តួចផ្តើម ៣.១.** តំបន់សេវាអ៊ីនធើណិតឥតគិតថ្លៃ ក្នុងទីក្រុង និងជនបទ ជាពិសេសសម្រាប់ប្រជាជនក្រីក្រ និងក្រុមដែលមិនមានឱកាសទទួលបានសេវាកម្មអ៊ីនធើណែត<br>**គំនិតផ្តួចផ្តើម ៣.២.** កម្មវិធីបណ្តុះបណ្តាលអចិន្ត្រៃយ៍ស្តីពីចំណេះដឹងកុំព្យូទ័រ និងបច្ចេកវិទ្យា សម្រាប់ប្រជាពលរដ្ឋ ជាពិសេសយុវជន តាមរយៈ "ទូតទីក្រុងឌីជីថល" | **ការលើកកម្ពស់ "បរិយាបន្ន"**<br>១១. កសាងចំណេះដឹងស្តីពីប្រព័ន្ធផ្សព្វផ្សាយ/ព័ត៌មាន/ទិន្នន័យក្នុងចំណោម អ្នកពាក់ព័ន្ធទាំងអស់<br>១២. កសាងសមត្ថភាពរបស់ពលរដ្ឋក្នុងការរាយការណ៍ព័ត៌មានអំពីបញ្ហា និងកង្វល់របស់សហគមន៍ពួកគេ<br>១៣. បើកការតភ្ជាប់អ៊ីនធឺណេតនៅទូទាំងក្រុងព្រះសីហនុដោយផ្អែកលើមូលដ្ឋានបរិយាបន្ន<br>១៤. ការអនុវត្តការដាក់បញ្ចូល ដើម្បីធានាបាននូវភាពស្មើភាព និងសមភាព យេនឌ័រ |


© រដ្ឋបាលខេត្តព្រះសីហនុ

# ៤. គំនិតផ្តួចផ្តើមឆ្លាតវៃទាំង១៣ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន សម្រាប់ក្រុងព្រះសីហនុ

គំនិតផ្តួចផ្តើមឆ្លាតវៃទាំង១៣ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន ត្រូវបានរៀបចំឡើងស្របតាម គោលការណ៍សន្តិសុខមនុស្ស ដែលផ្តោតសំខាន់លើមនុស្ស មានលក្ខណៈគ្រប់ជ្រុងជ្រោយ សមស្របតាម បរិបទជាក់ស្តែង និងផ្តោតលើយន្តការក្នុងការបង្ការ។ ទន្ទឹមនឹងនេះ វាក៏ឆ្លើយតបទៅនឹងអនុសាសន៍ យុទ្ធសាស្ត្រសន្តិសុខមនុស្សចំនួន១០ ដែលសំដៅលើកកម្ពស់បរិយាបន្ន និរន្តរភាព និងការចូលរួមប្រកប ដោយភាពឆ្លាតវៃផងដែរ។ យុទ្ធសាស្ត្រអនុវត្តន៍នៃគំនិតផ្តួចផ្តើមនីមួយៗ តម្រូវឱ្យមានយន្តការ ដើម្បីជំរុញ ការការពារ និងផ្តល់អំណាច ដល់ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋានដោយយកចិត្តទុកដាក់ជាពិសេសចំពោះប្រជាពលរដ្ឋក្រីក្រ។

គំនិតផ្តួចផ្តើមទាំងនេះ ត្រូវបានបង្កើតឡើងដើម្បីជំរុញសម្ព័ន្ធភាពថ្មីមួយរវាងប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន ដើម្បីអនុវត្តវិធីសាស្ត្រទីក្រុងឆ្លាតវៃដែលផ្តោតលើមនុស្ស តាមទស្សនទានសិទ្ធិមនុស្ស ដោយលើក កម្ពស់ការដាក់បញ្ចូលក្មេងស្រី ស្ត្រី យុវជន និងក្រុមប្រជាជនដែលខ្វះឱកាស ទៅក្នុងការអនុវត្តគំនិតផ្តួចផ្តើមទាំងអស់នេះ។

គំនិតផ្តួចផ្តើមនីមួយៗ ត្រូវបានបង្កើតឡើងដោយបង្កប់នូវគោលការណ៍ណែនាំទាំង៣ ដែលបានពន្យល់ នៅក្នុងជំពូក៣.១ និងត្រូវបានរៀបចំជាក់លាក់ដូចខាងក្រោម៖

- ដាក់ពលរដ្ឋនៅចំណុចកណ្តាលនៃយន្តការទីក្រុងឆ្លាតវៃ និងផ្តល់នូវឌីជីថលនីយកម្មដើម្បីដោះស្រាយ បញ្ហាប្រឈមជាក់លាក់ (គោលការណ៍ផ្តោតលើមនុស្ស)។
- បង្កើតវិធីសាស្ត្រចម្រុះ ដើម្បីឱ្យប្រជាជនទាំងអស់បានចូលរួម និងផ្តល់នូវសកម្មភាពសមស្របសម្រាប់សហគមន៍ក្រីក្រ និងជនងាយរងគ្រោះ (គោលការណ៍សិទ្ធិមនុស្ស)។
- ប្រមើលមើលឱកាសនៃការចូលរួម ទាំងការចូលរួមនិម្មិត និងចូលរួមដោយផ្ទាល់សម្រាប់ស្ត្រី និងក្មេងស្រីដើម្បីជួយសម្រួលដល់ដំណើរការបរិយាប្ន័ន (ផ្តោតលើក្មេងស្រីនិងស្ត្រីសម្រាប់ទីក្រុងឆ្លាតវៃ)។

## ៤.១. គំនិតផ្តួចផ្តើម ១.១.

### វេទិកាក្រុងព្រះសីហនុឆ្លាតវៃ តាមរយៈការចូលរួមអេឡិចត្រូនិក

វេទិកាឌីជីថលសម្រាប់ "ការចូលរួមអេឡិចត្រូនិក" នឹងត្រូវបានបង្កើតឡើង ដើម្បីជំរុញឱ្យមានការ ចូលរួមពីសាធារណៈ និងប្រជាពលរដ្ឋមូលដ្ឋាន ក្នុងទិដ្ឋភាពចូលរួមការអភិវឌ្ឍសំខាន់ៗនៅក្នុងក្រុងព្រះសីហនុ។ វេទិកាឌីជីថលនេះ នឹងផ្តល់នូវច្រកនៃការចូលរួមចំនួន ២ ៖

1. *ពីសាលាក្រុង និងរដ្ឋបាលមូលដ្ឋាន(វិធីសាស្ត្រTop-down approach)៖ វិធីសាស្ត្រនេះ តម្រូវឱ្យស្ថាប័នសាធារណៈជាអ្នកចាប់ផ្តើមអំពាវនាវឱ្យមានការចូលរួមពីសាធារណៈដើម្បីស្តាប់ពីតម្រូវការ និងការយល់ឃើញរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ប្រធានបទពាក់ព័ន្ធនានា នឹងត្រូវបានលើកឡើងដើម្បីឱ្យប្រជាពលរដ្ឋ អាចចូលរួមបញ្ចេញមតិ និងកំណត់អាទិភាពសកម្មភាព/បញ្ហាដែលពាក់ព័ន្ធខ្លាំងបំផុត។*

*២. រៀបចំសកម្មភាពដើម្បីធ្វើការផ្លាស់ប្តូរជាមួយគ្នា (វិធីសាស្ត្រ Bottom-up approach)៖ ក្នុងវិធីសាស្ត្រនេះ ប្រជាពលរដ្ឋគ្រប់រូប តំណាងសហគមន៍មូលដ្ឋាន សមាគម និងអង្គការមិនមែនរដ្ឋាភិបាល អាចលើកសំណើពីបញ្ហា ឬប្រធានបទដើម្បីធ្វើការពិភាក្សាជាមួយរដ្ឋបាលក្រុង និងមូលដ្ឋាន។ អាជ្ញាធរមូលដ្ឋាននឹងវាយតម្លៃលើបញ្ហាទាំងនោះហើយប្រសិនបើវាត្រូវបានពិចារណាថាពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាននឹងធ្វើការកោះអញ្ជើញឱ្យចូលរួមដោយបើកចំហ ដើម្បីប្រមូលគំនិត យោបល់ និងព័ត៌មានដែលពាក់ព័ន្ធនានា ពីសាធារណជន។ ការចូលរួមអាចនឹងធ្វើឡើងតាមប្រព័ន្ធឌីជីថល ព្រមទាំងកិច្ចប្រជុំផ្ទាល់ ដែលភាគីពាក់ព័ន្ធនានា និងប្រជាពលរដ្ឋនឹងត្រូវបានអញ្ជើញឱ្យចូលរួម។ ផ្នែកមួយនៃវេទិកាសម្រាប់ការចូលរួមអេឡិចត្រូនិច នឹងត្រូវបានរៀបចំជាពិសេស សម្រាប់ស្ត្រី និងក្មេងស្រី ដើម្បីប្រមូលព័ត៌មានពីតម្រូវការ មតិយោបល់ និងទស្សនទានរបស់ពួកគេ និងដើម្បីធានាឱ្យបាននូវការធ្វើទំនាក់ទំនងប្រកបដោយសុវត្ថិភាព និងដោយសេរីសម្រាប់ពួកគេ។*

## ៤.២. គំនិតផ្តួចផ្តើម ១.២.

### វេទិកាអភិបាលកិច្ចអេឡិចត្រូនិក សម្រាប់ប្រជាពលរដ្ឋ

វេទិកា “អភិបាលកិច្ចអេឡិចត្រូនិក” នឹងត្រូវបង្កើតឡើង ដែលប្រជាជនក្នុងមូលដ្ឋានអាចពិគ្រោះយោបល់ ព្រមទាំងស្វែងរកព័ត៌មានទាក់ទងនឹងនីតិវិធីនៃការកាន់កាប់ដីធ្លី ការស្វែងរកលំនៅដ្ឋាន បរិក្ខារអប់រំ ប័ណ្ណគ្រួសារ សេវាកម្មសុខភាព ការប្រមូលសំណល់ ឱកាសសេដ្ឋកិច្ចក្នុងមូលដ្ឋាន និងការធ្វើដំណើរ រវាងទីក្រុង-ជនបទ។ ល។

វេទិកាអភិបាលកិច្ចអេឡិចត្រូនិកនេះ នឹងក្លាយជាគេហទំព័រមេ និងជាវិបផតថល (Web portal) ដែលរដ្ឋបាលមូលដ្ឋានប្រើប្រាស់ដើម្បីជំរុញមុខងារទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន សម្រាប់ក្រុងព្រះសីហនុ។

វេទិកាចូលរួមឌីជីថលសម្រាប់ “ការចូលរួមអេឡិចត្រូនិក” (ក្នុងគំនិតផ្តួចផ្តើម១.១) និងគំនិតផ្តួចផ្តើម ឆ្លាតវៃដទៃទៀត នឹងត្រូវបានលើកកម្ពស់ និងដាក់ជាផ្នែកមួយនៃវិបផតថលនេះ។

អង្គភាពនវានុវត្តន៍មួយរបស់ក្រុង ដែលមានបុគ្គលិកច្បាស់លាស់ គួរត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រង សេវាកម្មតាមអ៊ីនធើណិត និងឆ្លើយតបទៅនឹងសំណូមពររបស់ប្រជាពលរដ្ឋ។

សកម្មភាពអភិបាលកិច្ចអេឡិចត្រូនិកនឹងត្រូវបានលើកកម្ពស់ តាមរយៈយុទ្ធនាការផ្សព្វផ្សាយតាម អ៊ីនធើណិត និងការប្រជុំផ្សព្វផ្សាយដោយផ្ទាល់។ ការប្រជុំដោយផ្ទាល់នឹងត្រូវបានរៀបចំ ឡើងនៅតាមសហគមន៍ដែលខ្វះខាត ដើម្បីគាំទ្រដល់ប្រជាជនក្រីក្រ និងសហគមន៍ ដែលងាយរងគ្រោះក្នុង ការរៀនសូត្រពីរបៀបប្រើប្រាស់សេវាកម្មអេឡិចត្រូនិក។ ការប្រជុំទាំងនេះ ជាសកម្មភាពដែលជំរុញការចូលរួមរបស់ប្រជាពលរដ្ឋក្រីក្រ និងក្រុមជនដែលងាយរងគ្រោះ ក្នុងការទាមទារសិទ្ធិ និងលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេ។

## ៤.៣.គំនិតផ្តួចផ្តើម ១.៣.

### មជ្ឈមណ្ឌលសហគមន៍ឆ្លាតវៃ

មជ្ឈមណ្ឌលសហគមន៍ឆ្លាតវៃ នឹងត្រូវបានបង្កើត និងរៀបចំនៅក្នុងមូលដ្ឋានមួយចំនួន នៃក្រុងព្រះសីហនុ ដើម្បីឆ្លើយតបនឹងតម្រូវការសហគមន៍ ហើយរដ្ឋបាលមូលដ្ឋាននឹងចូលរួមដើម្បីចែក រំលែកអំពីបញ្ហា និងដំណោះស្រាយចំពោះស្ថានភាពភាពអាសន្ន និងបញ្ហានានានៅក្នុងទីក្រុង។

មជ្ឈមណ្ឌលសហគមន៍ឆ្លាតវៃ នឹងជំរុញការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកម្រិតមូលដ្ឋាន ហើយនឹងក្លាយជាកន្លែងសម្រាប់ពិភាក្សាអំពីបញ្ហា និងកត្តាប្រឈមដែលកើតឡើងក្នុងសហគមន៍ ព្រមទាំង សម្រាប់ចែករំលែកពីគំនិត និងការយល់ឃើញនានា ដែលត្រូវដាក់ជូនអាជ្ញាធរមូលដ្ឋានតាមរយៈ “ការចូលរួមអេឡិចត្រូនិក” (គំនិតផ្តួចផ្តើម ១.១)។

ក្រុមការងារផ្តោតលើស្ត្រី/ក្មេងស្រី នឹងត្រូវបានបង្កើតឡើងនៅក្នុងសហគមន៍ ដើម្បីស្តាប់ពីកង្វល់ ឬ តម្រូវការរបស់ស្ត្រី និងក្មេងស្រី និងសហការរៀបចំដំណោះស្រាយទាក់ទងនឹងយេនឌ័រ ដើម្បីធានាថាស្ត្រី និងក្មេងស្រីនឹង

ទទួលបាននូវសេវាកម្ម និងបរិក្ខារទីក្រុងដោយស្មើភាព។

បង្កើតក្រុមអ្នកសម្របសម្រួលមួយ ដើម្បីគាំទ្រដល់សហគមន៍មូលដ្ឋាន ក្នុងដំណើរការ នៃការចូលរួម ដើម្បីបង្កើតកិច្ចសហការ និងចែករំលែកគំនិតអំពីសេវាកម្ម បរិក្ខារ ឬគំនិតផ្តួចផ្តើមថ្មីៗសម្រាប់ប្រជាពលរដ្ឋក្នុងទីក្រុងដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងមូលដ្ឋាន និងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ របស់ ប្រជាពលរដ្ឋ។

## ៤.៤. គំនិតផ្តួចផ្តើម ១.៤.

### ការធ្វើផែនការទីក្រុងឆ្លាតវៃសម្រាប់យុវជន

យុវជននឹងចូលរួមក្នុងមណ្ឌលពិសោធន៍បែបឌីជីថលតាមរយៈល្បែងកំសាន្ត ដើម្បីកំណត់សកម្មភាព រៀបចំផែនការទីក្រុង និងរៀបចំទីក្រុងឡើងវិញ។ វិធីសាស្រ្តនេះពឹងផ្អែកលើការចូលរួមដែលនឹងត្រូវធ្វើឡើងតាមរយៈការប្រើប្រាស់ការកំសាន្ត និងលេងហ្គេម ដើម្បីរៀបចំទីក្រុងឡើងវិញ និងពិសោធន៍ការច្នៃប្រឌិតចំពោះការរៀបចំទីកន្លែងសាធារណៈក្នុងទីក្រុង។

ដំណើរការដែលមានការចូលរួមមួយនឹងត្រូវបង្កើតឡើងដោយផ្សារភ្ជាប់ជាមួយមជ្ឈមណ្ឌលសហគមន៍ ឆ្លាតវៃក្រុងព្រះសីហនុ (គំនិតផ្តួចផ្តើម ១.៣) និងវេទិកាចូលរួមអេឡិចត្រូនិក (គំនិតផ្តួចផ្តើម ១.១) ដើម្បីប្រមូលព័ត៌មានពីតម្រូវការ បំណងប្រាថ្នា និងការយល់ដឹង ដើម្បីគ្រប់គ្រងឱ្យបានល្អប្រសើរនូវសកម្មភាពរៀបចំផែនការទីក្រុងនៅក្រុងព្រះសីហនុ។

កម្មវិធីពិសោធន៍ឌីជីថលនឹងត្រូវបង្កើតឡើង ហើយយុវជននឹងត្រូវបានអញ្ជើញឱ្យសាកល្បងទទួលបទពិសោធន៍នៃការផ្លាស់ប្តូរទីក្រុងដោយប្រើហ្គេមនិម្មិត (VR) តាមរយៈវិធីសាស្រ្ត "មួយប្លុកម្តងៗ"[៥] ដែលប្រើវីដេអូហ្គេម ដូចជា Minecraft ដើម្បីរៀបចំទីក្រុង និងតំបន់ជនបទឡើងវិញ។ UN-Habitat បានពិសោធន៍រួចហើយនូវគំនិតផ្តួចផ្តើមមួយប្លុកម្តងៗ ដើម្បីរៀបចំតំបន់ទីក្រុងនៅក្នុងប្រទេស មួយចំនួន ហើយក្រុងព្រះសីហនុក៏អាចទទួលបានអត្ថប្រយោជន៍ពីបទពិសោធន៍នេះដែរ។

ថ្មីៗនេះ UN-Habitat បានដាក់ឱ្យដំណើរការនូវ "ប្រអប់ឧបករណ៍ទីក្រុងសម្រាប់ស្រ្តី" ដែលជាវេទិកា មានមូលដ្ឋានលើការលេងកម្សាន្តឌីជីថល ដើម្បីជំរុញការគិតឡើងវិញ និងរៀបចំផែនការ ទីក្រុងតាមទស្សនទានយេនឌ័រ។ វិធីសាស្រ្តនេះក៏គួរត្រូវបានប្រើផងដែរនៅក្រុងព្រះសីហនុ ដើម្បីដាក់ បញ្ចូលក្មេងស្រី និងស្រ្តីក្នុងការពិសោធន៍សមស្រប ដើម្បីទទួលបាន និងស្តាប់គំនិតរបស់ពួកគេទាក់ទង នឹងបញ្ហាទីកន្លែងសាធារណៈក្នុងទីក្រុងបរិក្ខារទឹកស្អាត និងអនាម័យ ការដឹកជញ្ជូន និងបញ្ហាសុវត្ថិភាព។

## ៤.៥. គំនិតផ្តួចផ្តើម ២.១.

### ផែនទីបរិស្ថាន (ការគ្រប់គ្រងសំណល់, ទឹកជំនន់...) តាមរយៈព័ត៌មានដែលមានប្រភពពីមហាជន តាមប្រព័ន្ធឌីជីថល

ផែនទីដែលមានប្រភពពីមហាជននឹងត្រូវបានបង្កើតឡើង ដើម្បីកំណត់ស្ថានភាពអាសន្នផ្នែកបរិស្ថាននៅក្រុងព្រះសីហនុ ជាពិសេសចំពោះតំបន់ជាយក្រុង តំបន់មិនទាន់រៀបរយ និងតំបន់ក្រៅផ្លូវការផ្សេងទៀត ដើម្បីជាជំនួយដល់អាជ្ញាធរមូលដ្ឋាន ក្នុងការឆ្លើយតបឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា ក្នុងការថែរក្សាទីក្រុង ការគ្រប់គ្រងបរិស្ថាន និងលើកកម្ពស់ការគ្រប់គ្រងរួមគ្នានៅកម្រិតសហគមន៍ តាមយុទ្ធសាស្រ្តពីក្រោមទៅលើ បន្ថែមលើយុទ្ធសាស្រ្តពីលើទៅក្រោម (bottom-up strategy plus top-down approach)។

ការប្រមូលទិន្នន័យតាមរយៈប្រព័ន្ធ ICT មានប្រសិទ្ធភាពជាងការប្រមូលទិន្នន័យតាមបែបប្រពៃណីក្នុងការគ្រប់គ្រងបរិស្ថាន។ ប្រជាពលរដ្ឋក្នុងមូលដ្ឋានអាចចូលរួមផ្តល់នូវទិន្នន័យ និងព័ត៌មានពីបាតុភូតដែលកំពុងតែកើតឡើងនៅតាមទីតាំងនានា ដោយផ្ទាល់ ជាពិសេសទាក់ទងនឹងទឹកជំនន់ និង/ឬការគ្រប់គ្រងសំណល់។ ទិន្នន័យដែលមានប្រភពពីមហាជនទាំងនេះនឹងត្រូវបានបញ្ចូលភ្លាមៗទៅក្នុងផែនទីលើប្រព័ន្ធអ៊ីនធើណិត ដើម្បីផ្តល់ព័ត៌មានទាន់ពេលវេលាសម្រាប់មនុស្សគ្រប់រូបដែល កំពុងស្វែង

៥ https://www.blockbyblock.org/

រកព័ត៌មានភ្លាមៗ។

លំហនិម្មិត (virtual space ) សម្រាប់ការបង្កើត/ច្នៃប្រឌិតរួមគ្នា ដែលទាក់ទងនឹងបរិស្ថាន កសិកម្ម ម្ហូបអាហារ ព្រមទាំងសុខភាពនឹងត្រូវបានបង្កើតឡើងនៅក្នុងមជ្ឈមណ្ឌលសហគមន៍ឆ្លាតវៃ (គំនិតផ្តួច ផ្តើម ១.៣)។ ស្ត្រី ក្មេងស្រី និងក្រុមមនុស្សដែលងាយរងគ្រោះ នឹងត្រូវបានលើកទឹកចិត្តឱ្យចូលរួមស្នើគំនិតរួមគ្នាដើម្បីលើកកម្ពស់សកម្មភាព/សេវាកម្ម/ការអនុវត្តក្នុងមូលដ្ឋាន។

ផែនទី ដែលមានប្រភពពីមហាជននឹងត្រូវបានដាក់បញ្ចូលទៅក្នុងវេទិកា អភិបាលកិច្ចអេឡិចត្រូនិក (គំនិតផ្តួចផ្តើម ១.២)។

## ៤.៦. គំនិតផ្តួចផ្តើម ២.២.

### ដំណោះស្រាយឆ្លាតវៃសម្រាប់ប្រជាជនចំណាកស្រុក

នៅក្រុងព្រះសីហនុ ការដឹកជញ្ជូនសាធារណៈនៅមិនទាន់មានគ្រប់គ្រាន់ និងខ្វះខាតក្នុងតំបន់មួយចំនួន។ សេវាកម្មដឹកជញ្ជូនឯកជន និងសេវាកម្មដឹកជញ្ជូនក្រៅប្រព័ន្ធត្រូវបានបង្កើតឡើង ដើម្បីបំពេញតម្រូវការ ចល័តរបស់ប្រជាជនក្នុងតំបន់។

កម្មវិធីផែនទីអនឡាញ (online map) ដែលមានប្រភពពីមហាជន ត្រូវបានភ្ជាប់ទៅនឹងឧបករណ៍ឌីជីថលដូចជាផែនទីហ្គូហ្គោល (Google map) នឹងត្រូវបានបង្កើតឡើង ដើម្បីប្រមូល និងផ្តល់នូវរាល់ព័ត៌មានស្តីពីការផ្តល់សេវាដឹកជញ្ជូនពីវិស័យឯកជន និងក្រៅផ្លូវការ។

ការធ្វើដំណើររួមគ្នា (រថយន្តសាធារណៈ) នឹងត្រូវបានលើកទឹកចិត្ត ដោយការបង្កើតសហគមន៍អ្នកដំណើរអនឡាញដោយប្រើឧបករណ៍វេទិកាចូលរួមអេឡិចត្រូនិក (គំនិតផ្តួចផ្តើម ១.១)។

ការប្រជុំអំពីការធ្វើដំណើរ នឹងត្រូវរៀបចំឡើង ដើម្បីស្តាប់ពីតម្រូវការ និងផ្លូវធ្វើដំណើរសំខាន់ៗរបស់ប្រជាពលរដ្ឋតាមរយៈយុទ្ធសាស្ត្រមជ្ឈមណ្ឌលសហគមន៍ឆ្លាតវៃ ដូចដែលបានពិពណ៌នានៅក្នុងគំនិត ផ្តួចផ្តើម ១.៣។ ទិន្នន័យស្តីពីការធ្វើដំណើរ និងការដឹកជញ្ជូននេះក៏អាចប្រើប្រាស់ដើម្បីវាស់ស្ទង់ លទ្ធភាពក្នុងការទទួលបានសេវាសុខភាព (គំនិតផ្តួចផ្តើម២.៦) និងលំហបៃតងព្រមទាំងដើម្បី វាស់ស្ទង់ សមាមាត្រប្រជាជនដែលមានលទ្ធភាពទទួលបានសេវាដឹកជញ្ជូនសាធារណៈឬសេវាផ្សេងៗទៀតផងដែរ។

ក្រុមការងារដែលផ្តោតលើការធ្វើចំណាកស្រុក ប្រកបដោយសុវត្ថិភាពសម្រាប់ប្រជាជនចំណាកស្រុកក្នុងទីក្រុង ជាក្មេងស្រី និងស្ត្រីនឹងត្រូវរៀបចំឡើងតាមរយៈការប្រជុំផ្ទាល់ និងតាមវេទិកាប្រជុំអនឡាញ។ ប្រព័ន្ធធ្វើដំណើររួមគ្នា និងការផ្តល់សេវាដឹកជញ្ជូនសាធារណៈ និងឯកជនសម្រាប់ ស្ត្រី នឹងត្រូវបាន លើកកម្ពស់។

## ៤.៧. គំនិតផ្តួចផ្តើម ២.៣.

### កសិកម្ម និងស្បៀងអាហារឆ្លាតវៃ

ក្រុងព្រះសីហនុ មានឆន្ទៈក្នុងការធានាឱ្យបាននូវការទទួលបានអាហារក្នុងស្រុក ដែលគាំទ្រដល់ការ ផលិត និងការចែកចាយក្នុងស្រុក។

ខ្សែសង្វាក់ម្ហូបអាហារនឹងត្រូវបានធានានៅក្នុងកម្មវិធីទីក្រុងឆ្លាតវៃ ដោយចាប់ផ្តើមពីការដាំដុះសរីរាង្គ (រាប់បញ្ចូលការរៀបចំសួនបន្លែក្នុងទីក្រុង) រហូតដល់ខ្សែសង្វាក់ចែកចាយប្រកបដោយនិរន្តរភាព (ការចែកចាយតាមផ្សារទំនើប ទីផ្សារ សហគមន៍ ទីផ្សារក្រៅផ្លូវការ។ ល។) ការកែច្នៃ និងការរៀបចំ ម្ហូបអាហារ (សេវារៀបចំអាហារអាហារដ្ឋាន)។

វេទិកាឌីជីថលសម្រាប់អ្នកផលិត អ្នកចែកចាយ និងអ្នកទទួលទានអាហារនឹងត្រូវបានបង្កើតឡើង ដើម្បីគាំទ្រដល់សេដ្ឋកិច្ច-កសិអាហារក្នុងស្រុក ទាំងនៅជនបទ និងទីក្រុង។ វេទិកានេះនឹងកំណត់អត្តសញ្ញាណតំបន់ទីក្រុង និងជនបទសាធារណៈ និងឯកជន ដើម្បីបង្កើនការដាំដុះដោយសេរី ជាពិសេស ឆ្លើយតបនឹងតម្រូវការរបស់ប្រជាជនដែលមានប្រាក់ចំណូលទាប និងងាយរងគ្រោះ។

មជ្ឈមណ្ឌលបណ្តុះបណ្តាលមួយដែលហៅថា“ពីអាហារទៅសុខភាព៖ ការគាំទ្រយុត្តិធម៌សង្គម និងសមធម៌” នឹងត្រូវបានបង្កើតឡើង តាមរយៈ វិធីសាស្ត្រចម្រុះ ដែលក្នុងនោះកិច្ចប្រជុំផ្ទាល់នឹងត្រូវបានបញ្ចូលជាមួយបទពិសោធន៍

និម្មិត/អនឡាញ។ មជ្ឈមណ្ឌលនេះនឹងផ្តល់ជូននូវកម្មវិធីបណ្តុះបណ្តាល ស្តីពីបច្ចេកទេសកសិកម្មទំនើប និងការដាំដុះសរីរាង្គ ព្រមទាំងកម្មវិធីសិក្សាពីសហគ្រិនភាព ដើម្បីគាំទ្រដល់ទីផ្សារម្ហូបអាហារក្នុងស្រុក។

ដំណើរការសិក្សាជាក់លាក់ និងសហគមន៍រូបវន្ត-និម្មិតមួយ សម្រាប់ស្ត្រីក្នុងវិស័យកសិកម្ម ការដឹក ជញ្ជូនម្ហូបអាហារ និងការលក់អាហារនឹងត្រូវបានបង្កើតឡើង ដើម្បីបណ្តុះចំណេះដឹង និងផ្លាស់ប្តូរព័ត៌មានអំពីគម្រោងនានា។

ការដាក់ឱ្យដំណើរការ កម្មវិធីអាហារសុខភាពក្នុងស្រុកនឹងរួមចំណែកដល់ការទាក់ទាញភ្ញៀវទេសចរនៅក្នុងតំបន់ តាមរយៈការបង្កើន និងការកែលម្អផលិតកម្ម ការកែច្នៃ និងការរៀបចំម្ហូបអាហារ ព្រមទាំងការបង្កើតម៉ាក និងការផ្សព្វផ្សាយផលិតផលក្នុងស្រុក។ គំនិតផ្តួចផ្តើមនេះនឹងចូលរួមលើកកម្ពស់ ការផ្លាស់ប្តូរឥរិយាបថអ្នកប្រើប្រាស់ តាមរយៈការលើកទឹកចិត្តឱ្យប្រជាពលរដ្ឋទទួលទានរបបអាហារ សរីរាង្គ តាមរដូវកាលក្នុងស្រុក និងអាហារផ្អែកលើរុក្ខជាតិកាន់តែច្រើន ព្រមទាំងពង្រឹងការចូលរួមរបស់សហគមន៍មូលដ្ឋានផងដែរ។

គំនិតផ្តួចផ្តើមនេះនឹងត្រូវអនុវត្តរួមគ្នាជាមួយគំនិតផ្តួចផ្តើមមជ្ឈមណ្ឌលសហគមន៍ឆ្លាតវៃ (១.៣) និងគំនិតផ្តួចផ្តើមគំរូនៃការកាន់កាប់ដីធ្លី ដើម្បីកំណត់តំបន់សាធារណៈ និងឯកជនដែលត្រូវប្រើប្រាស់សម្រាប់ការដាំដុះ (២.៤)។

## ៤.៨. គំនិតផ្តួចផ្តើម ២.៤

### ដំណោះស្រាយឆ្លាតវៃ សម្រាប់លំនៅឋាន និងការកាន់កាប់ដីធ្លី

បណ្តាញសម្រាប់ “សិទ្ធិលំនៅឋាន និងដីធ្លី” នឹងត្រូវបង្កើតឡើងតាមរយៈ វិធីសាស្ត្រដែលមានការចូលរួមពីសហគមន៍ ដើម្បីពិភាក្សា និងវិភាគពីលទ្ធភាពនៃការទទួលបានលំនៅឋាន និងការធានាសិទ្ធិ កាន់កាប់ដីធ្លីសម្រាប់ប្រជាជនដែលមានប្រាក់ចំណូលទាប និងសម្រាប់ប្រជាជនគ្រប់រូប។ បណ្តាញ នេះនឹងរៀបចំផែនទីបង្ហាញពីលទ្ធភាពលំនៅឋានដែលសមស្របនឹងលទ្ធភាពប្រើប្រាស់សាធារណៈ និងឯកជន។

ទីផ្សារអចលនទ្រព្យឯកជននឹងត្រូវបានដាក់បញ្ចូលឱ្យមានការរៀបចំ និងផ្តល់លំនៅឋានដែលមាន តម្លៃសមរម្យ (សម្រាប់ជួល ឬលក់) សម្រាប់ក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះ។ អ្នកផ្គត់ផ្គង់លំនៅឋានឯកជនដែលចូលរួមក្នុងបណ្តាញ លំនៅឋានក្នុងតម្លៃអត្រាសមរម្យ “អត្រាសាមគ្គី” នឹងទទួលបានអត្ថប្រយោជន៍ពីរាជរដ្ឋាភិបាល ដូចជាការបញ្ចុះតម្លៃពន្ធ ឬឱកាស ទីផ្សារផ្សេងៗទៀត។

សំណង ក៏ដូចជាកម្មវិធីគាំទ្រអ្នកក្រីក្រសម្រាប់លំនៅឋាននឹងត្រូវឆ្លងកាត់ការពិភាក្សា និងការសហការ គ្រប់គ្រងដោយបណ្តាញ “សិទ្ធិលំនៅឋាន និងដីធ្លី” ដែលនឹងក្លាយជាការពិសោធន៍អចិន្ត្រៃយ៍ដើម្បី ធានាបាននូវលំនៅឋានក្នុងតម្លៃសមរម្យសម្រាប់ពលរដ្ឋទាំងអស់គ្នា។

គំរូកម្មសិទ្ធិសង្គម[7] (STDM) ជាឧបករណ៍គ្រប់គ្រងដីធ្លីដែលផ្តោតសំខាន់ក្នុងការរក្សាប្រយោជន៍សម្រាប់ពលរដ្ឋក្រីក្រ បង្កើតឡើងដោយ UN-Habitat នឹងត្រូវបង្កើតឡើង។ គំរូនេះ មានគោលបំណងគាំទ្រដល់សហគមន៍មូលដ្ឋាន និងបុគ្គលក្នុងការអភិវឌ្ឍឧបករណ៍គ្រប់គ្រងដីធ្លី និងគាំទ្រដល់ជនក្រីក្រ ឆ្លើយតបទៅនឹងគម្លាតបច្ចេកទេសដែលពាក់ព័ន្ធនឹងដីធ្លីដែលមិនបានចុះបញ្ជី ការធ្វើឱ្យប្រសើរឡើងនូវតំបន់អនាធិបតេយ្យ ឬតំបន់មិនទាន់រៀបរាយ ការតាំងទីលំនៅក្រៅផ្លូវការ ការគ្រប់គ្រងទីក្រុង និងជនបទ។

កិច្ចប្រជុំដែលមានការចូលរួម ការវាយតម្លៃអំពីយេនឌ័រ និងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព (អនុវត្តតាមគំនិតផ្តួចផ្តើម១.៣) នឹងត្រូវរៀបចំឡើងដើម្បីអនុវត្តគំរូ STDM ដែលក្នុងនោះការចុះបញ្ជី ព័ត៌មានដីធ្លីតាមរយៈកម្មវិធីកុំព្យូទ័របើកចំហ (open-source software)[៦] និងព័ត៌មានដីធ្លីនឹងត្រូវ បានផ្សាភ្ជាប់ទៅនឹងគំនិតផ្តួចផ្តើមផ្សេងទៀត ជាពិសេសទាក់ទងនឹងប្រព័ន្ធអភិបាលកិច្ច អេឡិចត្រូនិក (គំនិតផ្តួចផ្តើម ១.២) និងកសិកម្ម និងអាហារឆ្លាតវៃ

៦ https://stdm.gltn.net/downloads/

(គំនិតផ្តួចផ្តើម ២.៣)។

លំហានិម្មិតដែលបានកំណត់នៅក្នុងវេទិកាអភិបាលកិច្ចអេឡិចត្រូនិក (គំនិតផ្តួចផ្តើម ១.២) នឹងត្រូវបានបង្កើតឡើង សម្រាប់ផ្ទុក និងចែករំលែកព័ត៌មាន ឯកសារ និងទិន្នន័យទាក់ទងនឹងការប្រើប្រាស់ ដីធ្លី និងលំនៅឋាន។

## ៤.៩. គំនិតផ្តួចផ្តើម ២.៥.

### ទីក្រុងប្រកបដោយសុវត្ថិភាព

ការធ្វើវិភាគឌីជីថលអចិន្ត្រៃយ៍ផ្តោតលើសុវត្ថិភាពទីក្រុងដែលផ្អែកលើព័ត៌មានដែលមានប្រភពពី មហាជននឹងត្រូវបានបង្កើតឡើង។

វេទិកាឌីជីថលនឹងត្រូវបង្កើតឡើងដើម្បីឱ្យក្មេងស្រី និងស្ត្រី ចែករំលែកការយល់ដឹងរបស់ពួកគាត់ទាក់ទងនឹងសុវត្ថិភាពនៅទីសាធារណៈក្នុងទីក្រុង។ កត្តាមួយចំនួនដូចជា ភ្លើងបំភ្លឺ ភាពមើលឃើញ ភាពបើកចំហ ផ្លាកសញ្ញា វត្តមានរបស់មនុស្ស វត្តមានសន្តិសុខ ការដឹកជញ្ជូនសាធារណៈ ការឃ្លាំមើល ការថែទាំទីកន្លែង និងស្ថានភាពចិញ្ចើមផ្លូវ នឹងត្រូវបានវាយតម្លៃ។

កម្មវិធីទីក្រុងកាន់តែមានសុវត្ថិភាពសម្រាប់ពហុភាគីគួរត្រូវបានបង្កើតឡើង ក្នុងគោលបំណងបង្កើន ផលរួមរវាងទិន្នន័យ គោលនយោបាយ និងការតភ្ជាប់។ រដ្ឋាភិបាលមូលដ្ឋានគួរបង្កើតគោលនយោបាយ ឆ្លាតវៃ ដោយផ្អែកលើទិន្នន័យសុវត្ថិភាព និងប្រព័ន្ធតភ្ជាប់ទីក្រុងដែលមានសុវត្ថិភាពផ្អែកលើទូរស័ព្ទ ចល័ត។ តាមរយៈការប្រមូលទិន្នន័យ ការហៅទូរស័ព្ទសង្គ្រោះបន្ទាន់ដែលមានទីតាំងភូមិសាស្ត្រ និងមានពេលវេលាច្បាស់លាស់របាយការណ៍សេវាកម្មសង្គ្រោះបន្ទាន់ និងសេវាទទួលបណ្តឹង របស់ទីក្រុង រួមទាំងផែនទីបង្ហាញពីហេតុការណ៍នានា អាចត្រូវបានបង្កើតឡើង ដើម្បីបង្ហាញពីកន្លែងដែល មានបទឧក្រិដ្ឋ និងពេលវេលានៃហេតុការណ៍។ ទិន្នន័យនេះ អាចបញ្ចូលទៅក្នុងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ដើម្បីភ្ជាប់បញ្ហាសុវត្ថិភាព ទៅនឹងកង្វល់នៃការគ្រប់គ្រងទីក្រុង ដូចជាការអនុញ្ញាតច្បាប់សាងសង់ ការដឹកជញ្ជូន និងសេវាកម្មមូលដ្ឋាន ឬសូចនាករនានា ដូចជាស្ថានភាពចំណូល...ជាដើម។ ទិន្នន័យនេះ អាចប្រើប្រាស់ជាធាតុចូលដើម្បីបង្កើតក្របខ័ណ្ឌរៀបចំផែនការប្រើប្រាស់ដី(គំនិតផ្តួចផ្តើម ១.១, ១.៣, ១.៤) និងយុទ្ធសាស្ត្រសុវត្ថិភាពដោយផ្តោតលើការគ្រប់គ្រងផ្លូវ និងទីសាធារណៈ ដែលជាគន្លឹះនៃសុវត្ថិភាពសហគមន៍។

## ៤.១០. គំនិតផ្តួចផ្តើម ២.៦.

### ការថែទាំសុខភាពសម្រាប់សហគមន៍

ឧបករណ៍ដែលមានស្រាប់ ដើម្បីទទួលបានសេវាថែទាំសុខភាពសម្រាប់ជនក្រីក្រ ដែលគេហៅថា"ប័ណ្ណសមធម៌" នឹងត្រូវលើកកម្ពស់ដោយយុទ្ធសាស្ត្រទីក្រុងឆ្លាតវៃ ដែលមាននិរន្តរភាព និងបរិយាបន្ន។

ជំហ៊ានទី១ ព័ត៌មានវេជ្ជសាស្ត្រ ដែលមានប្រយោជន៍ នឹងត្រូវដាក់បញ្ចូលទៅក្នុងវេទិកាអភិបាលកិច្ច អេឡិចត្រូនិក ដែលបង្កើតឡើងក្រោម គំនិតផ្តួចផ្តើម ១.២។

ជំហ៊ានទី២ កម្មវិធីទូរស័ព្ទចល័ត ដែលមានឈ្មោះថា "កម្មវិធីថែទាំសុខភាពក្រុងព្រះសីហនុ" នឹងត្រូវបង្កើតឡើងដោយតម្រូវឱ្យមានការចូលរួមពីមណ្ឌលថែទាំសុខភាពឯកជន និងសាធារណៈ។ កម្មវិធីនេះ ដើរតួរជាកន្លែងដែលប្រជាជនអាចភ្ជាប់ទំនាក់ទំនងដោយផ្ទាល់ជាមួយព័ត៌មានវេជ្ជសាស្ត្រ តាមអ៊ីនធើណិត។ ទោះបីការប្រើសេវាកម្មតាមអ៊ីនធើណែតនេះ មិនអាចជំនួសការណាត់ជួបគ្រូពេទ្យ ផ្ទាល់ក៏ដោយ វាអាចកាត់បន្ថយតម្រូវការទៅជួបគ្រូពេទ្យ និងផ្តល់ព័ត៌មានបន្ថែមមួយចំនួន។

"មជ្ឈមណ្ឌលសុខភាពសហគមន៍" ផ្សាភ្ជាប់ទៅនឹង "មជ្ឈមណ្ឌលសហគមន៍ឆ្លាតវៃ" (គំនិតផ្តួចផ្តើម ១.៣) គឺជាកន្លែងបណ្តុះបណ្តាលអំពីសុខភាព សន្តិសុខស្បៀង និងអនាម័យ នឹងត្រូវរៀបចំឡើង ដើម្បីបង្កើនចំណេះដឹង ផ្តល់ព័ត៌មានសុខភាព និងលើកកម្ពស់ការបង្ការជំងឺ។

ឧបករណ៍ ដែលគាំទ្រដល់ក្មេងស្រី និងស្ត្រីដោយផ្តោតការយកចិត្តទុកដាក់ ជាពិសេសចំពោះស្ត្រីក្រីក្រ និងគ្រួសារដែលមានមេគ្រួសារជាស្ត្រី នឹងត្រូវបានបង្កើតឡើង ដែលក្នុងនោះកិច្ចប្រជុំផ្ទាល់ និងតាមបណ្តាញឌីជីថល ដែល

អាចឱ្យមានការពិភាក្សាអំពីបញ្ហារួម និងចែករំលែកដំណោះស្រាយនានា។

កម្មវិធីបណ្ដុះបណ្ដាលសម្រាប់ស្ត្រីមានផ្ទៃពោះ និងមាតា នឹងត្រូវរៀបចំឡើង ដើម្បីជំរុញកិច្ចសហការ រវាងមាតាក្នុងការថែទាំសុខភាពគ្រួសារ។ កម្មវិធីចម្រុះសម្រាប់អ្នកដឹកនាំសហគមន៍ជាស្ត្រី នឹងត្រូវ បានអនុវត្តផងដែរ ដើម្បីគាំទ្រដល់ការថែរក្សាសុខភាពដោយខ្លួនឯង និងជួយគ្នាទៅវិញទៅមកនៅ ក្នុងសហគមន៍ ជាពិសេសចំពោះអ្នកម្ដាយវ័យក្មេង។

គំនិតផ្ដួចផ្ដើម៣.១ដែលសំដៅផ្ដល់នូវតំបន់អ៊ីនធើណិតឥតគិតថ្លៃជាច្រើននៅក្នុងទីក្រុងនឹងធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានព័ត៌មានវេជ្ជសាស្ត្រ និងទំនាក់ទំនងជាមួយស្ថាប័នវេជ្ជសាស្ត្រ។

## ៤.១១. គំនិតផ្ដួចផ្ដើម ២.៧.

### ប្រព័ន្ធសេដ្ឋកិច្ចឆ្លាតវៃ ប្រកបដោយបរិយាបន្ន

ប្រព័ន្ធសេដ្ឋកិច្ចឆ្លាតវៃ ដែលមានបរិយាបន្ន នឹងត្រូវបានបង្កើតជាកម្មវិធីទូរស័ព្ទដែលភ្ជាប់ទៅនឹង វេទិកាអភិបាលកិច្ចអេឡិចត្រូនិក (គំនិតផ្ដួចផ្ដើម ១.២) និងការចូលរួមអេឡិចត្រូនិក (គំនិតផ្ដួចផ្ដើម ១.១) ព្រមទាំងភ្ជាប់ទៅនឹងផែនទីតាមអ៊ីនធើណែត ដែលមានស្រាប់ ដូចជាផែនទីហ្គូហ្គោល... ជាដើម ដើម្បីឱ្យទីផ្សារខ្នាតតូច មធ្យម ផ្លូវការ និងក្រៅផ្លូវការ អាចផ្សព្វផ្សាយផលិតផលរបស់ពួកគេ និងផ្ដល់ ព័ត៌មានដល់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរអំពីទីតាំងរបស់ពួកគេ។ កម្មវិធីនេះនឹងត្រូវបានភ្ជាប់ទៅ នឹងគំនិតផ្ដួចផ្ដើម ២.២ ដែលជាដំណោះស្រាយឆ្លាតវៃសម្រាប់ការបម្លាស់ទីក្នុងទីក្រុង ដើម្បីតភ្ជាប់ ទៅតំបន់ក្រីក្រក្នុងប្រជុំជន និងគំនិតផ្ដួចផ្ដើមផ្សេងៗទៀត ដូចជាគំនិតផ្ដួចផ្ដើម ២.៣ ដែលផ្ដោតលើ កសិកម្ម និងស្បៀងអាហារឆ្លាតវៃ និងគំនិតផ្ដួចផ្ដើម ៣.១ ដែលផ្ដល់នូវតំបន់ប្រើប្រាស់អ៊ីនធើណិតឥតគិតថ្លៃនៅជនបទ និងតំបន់ក្រៅផ្លូវការផងដែរ។

កម្មវិធីនេះនឹងដើរតួនាទីជាវេទិកាផ្សព្វផ្សាយគោលដៅទេសចរណ៍ក្នុងក្រុងព្រះសីហនុ ដោយលើកកម្ពស់ដំណើរផ្លាស់ប្ដូរដោយយុត្តិធម៌ និងស្មើភាពគ្នាដើម្បីទាក់ទាញទេសចរណ៍ប្រកបដោយ សុវត្ថិភាព និងនិរន្តរភាព។

វគ្គបណ្ដុះបណ្ដាល ស្ដីពីប្រព័ន្ធសេដ្ឋកិច្ចឆ្លាតវៃ ដែលមានបរិយាបន្នដោយផ្ដោតលើវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព និងឱកាសទីផ្សារ នឹងត្រូវបានរៀបចំឡើង ដើម្បីឱ្យអាជីវករលក់រាយ បានទទួលឱកាសបង្កើនចំណេះដឹងអំពីសិទ្ធិអាជីវកម្ម និងច្បាប់ពាក់ព័ន្ធ។

ក្រុមការងារជាក់លាក់មួយដែលផ្ដោតលើស្ត្រីនឹងត្រូវបង្កើតឡើង ដើម្បីបង្កើនសមត្ថភាពសេដ្ឋកិច្ច និងសមត្ថភាពធ្វើអាជីវកម្មរបស់ពួកគាត់។

## ៤.១២. គំនិតផ្ដួចផ្ដើម ៣.១.

### តំបន់សេវាអ៊ីនធើណែតឥតគិតថ្លៃក្នុងទីក្រុង និងជនបទ ជាពិសេសសម្រាប់ប្រជាជនក្រីក្រ និងក្រុមដែលមិនមានឱកាសទទួលបានសេវាកម្មអ៊ីនធើណែត

តំបន់ប្រជុំជន និងជនបទសំខាន់ៗនឹងត្រូវបានកំណត់ឡើង ដោយមានការសហការពីសហគមន៍មូលដ្ឋាន អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋដើម្បីកំណត់រកទីកន្លែងពេញនិយមបំផុតនៅក្នុងទីក្រុង ដើម្បី ផ្ដល់នូវសេវាអ៊ីនធើណែតដោយឥតគិតថ្លៃ។ ទីតាំងទាំងនោះនឹងត្រូវបានបែងចែកជាតំបន់ ដើម្បី ផ្ដល់សេវាអ៊ីនធើណិតដោយឥតគិតថ្លៃសំដៅធានាបាននូវប្រយោជន៍សម្រាប់សហគមន៍ក្រីក្រ និងក្រុមដែលងាយរងគ្រោះបំផុត។

សេវាអ៊ីនធើណិតក៏នឹងត្រូវបានផ្ដល់ដោយឥតគិតថ្លៃនៅតាមទីកន្លែងសាធារណៈនានា ដូចជា៖ មជ្ឈមណ្ឌលអប់រំ និងវប្បធម៌ មណ្ឌលសុខភាព បណ្ណាល័យ មជ្ឈមណ្ឌលកីឡា និងឧទ្យាននានានៅកណ្ដាលទីក្រុង និងជាយក្រុង។

គំនិតផ្ដួចផ្ដើមនេះ នឹងស្ថិតនៅក្នុងអាទិភាពកំពូលនៃទស្សនទានទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន សម្រាប់ក្រុងព្រះសីហនុ ដើម្បីសម្រេចបាននូវគំនិតផ្ដួចផ្ដើមផ្សេងទៀត ដែលពឹងផ្អែកលើការប្រើប្រាស់អ៊ីនធើណិតជាឧបករណ៍ជំរុញបរិយាបន្នសម្រាប់ប្រជាពលរដ្ឋគ្រប់រូប។

## ៤.១៣. គំនិតផ្តួចផ្តើម ៣.២.

### កម្មវិធីបណ្តុះបណ្តាលអចិន្ត្រៃយ៍ អំពីចំណេះដឹងកុំព្យូទ័រ និងបច្ចេកវិទ្យាសម្រាប់ប្រជាពលរដ្ឋ ជាពិសេសយុវជនតាមរយៈ «ទូតទីក្រុងឌីជីថល»

កិច្ចសហការអចិន្ត្រៃយ៍ជាមួយមជ្ឈមណ្ឌលអប់រំ និងវិស័យសិក្សាធិការនឹងត្រូវបង្កើតឡើង ដើម្បី ធានាបាននូវការអប់រំគ្រប់គ្រាន់ ទាក់ទងនឹងបច្ចេកវិទ្យាថ្មីៗ វិធីសាស្រ្តទីក្រុងឆ្លាតវៃ និងចំណេះដឹង កុំព្យូទ័រ។

កម្មវិធីជាក់លាក់មួយសម្រាប់សហគមន៍ក្នុងតំបន់នឹងត្រូវបានបង្កើតឡើង ជាផ្នែកមួយមជ្ឈមណ្ឌលសហគមន៍ឆ្លាតវៃ (គំនិតផ្តួចផ្តើម ១.៣) ដើម្បីផ្តល់ការអប់រំពីការប្រើប្រាស់ឌីជីថល និងបច្ចេកវិទ្យា នៅក្នុងតំបន់ទីក្រុង និងជនបទ ដែលខ្វះខាតតាមរយៈកម្មវិធី "ទូតទីក្រុងឌីជីថល" ដែលមានគោល បំណងផ្តល់ឱកាសឱ្យយុវជនចូលរួមគាំទ្រក្នុងកម្មវិធីអប់រំ និងការកសាងសមត្ថភាពសម្រាប់ ប្រជាពលរដ្ឋទាំងអស់។

ក្រោយពេលជ្រើសរើស "ទូតទីក្រុងឌីជីថល" នឹងត្រូវបានបណ្តុះបណ្តាលអំពីគោលការណ៍រួមនៃទីក្រុង ឆ្លាតវៃដែលផ្តោតលើមនុស្ស ទស្សនទានសិទ្ធិមនុស្សសម្រាប់ទីក្រុងឆ្លាតវៃ និងវិធីសាស្រ្តយេនឌ័រ ក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ។ ការដឹកនាំប្រជាជនឱ្យទទួលបានអត្ថប្រយោជន៍ពីវេទិកាអភិបាលកិច្ច អេឡិចត្រូនិក ការចូលរួមអេឡិចត្រូនិក ការចូលរួមដល់គំនិតផ្តួចផ្តើមដែលពាក់ព័ន្ធនឹងការផ្តល់ព័ត៌មានដែលមានប្រភពពីមហាជន ព្រមទាំងការទទួលបានព័ត៌មានអំពីសុខភាព សេដ្ឋកិច្ច ការផលិតម្ហូបអាហារ ជាគោលដៅសំខាន់សម្រាប់ទូតទីក្រុងឌីជីថលក្នុងការចូលរួមលើកកម្ពស់ ការអនុវត្តគំនិតផ្តួចផ្តើមទាំង ១៣ ដែលមាននៅក្នុង "ទស្សនទានទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន"។

ទូតទីក្រុងឌីជីថល នឹងធ្វើការសហការជាមួយបុគ្គលិកនៃអង្គភាពនវានុវត្តន៍ និងអ្នកសម្របសម្រួលសហគមន៍។ ពួកគេក៏នឹងចូលរួមយ៉ាងសកម្ម នៅក្នុងមជ្ឈមណ្ឌលសហគមន៍ឆ្លាតវៃ (គំនិតផ្តួចផ្តើម ១.៣) និងនៅក្នុងការរៀបចំផែនការទីក្រុងឆ្លាតវៃសម្រាប់យុវជន (គំនិតផ្តួចផ្តើម ១.៤)។



© រដ្ឋបាលខេត្តព្រះសីហនុ

# ៥. គន្លឹះសំខាន់ៗសម្រាប់ការអនុវត្ត "ទស្សនទានទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន នៅក្រុងព្រះសីហនុ"

ដើម្បីធានានូវការអនុវត្ត ទស្សនទានទីក្រុងឆ្លាតវៃនៅក្រុងព្រះសីហនុ ដោយរលូន និងទទួលបានប្រសិទ្ធភាពខ្ពស់ ខាងក្រោមនេះជាគន្លឹះសំខាន់ៗ ដែលអាចយកប្រើប្រាស់បាន៖

១. ***ការកសាង សមត្ថភាពសម្រាប់បុគ្គលិកស្ថាប័នសាធារណៈ៖*** *បុគ្គលិកអាជ្ញាធរមូលដ្ឋានមានតួនាទីយ៉ាង សំខាន់ក្នុងការជំរុញដំណើរការអនុវត្តទីក្រុងឆ្លាតវៃក្រុងព្រះសីហនុដូច្នេះហើយការអភិវឌ្ឍសមត្ថភាពលើការរៀបចំឌីជីថលនីយកម្ម ចំណេះដឹងកុំព្យូទ័រ និងឱកាសឌីជីថលថ្មីៗ សម្រាប់បុគ្គលិកស្ថាប័ន សាធារណៈគឺជាចំណុចចាប់ផ្តើម និងជាបុរេលក្ខខណ្ឌសម្រាប់ការអនុវត្តយុទ្ធសាស្ត្រទីក្រុងឆ្លាតវៃ។*

២. ***អង្គភាពនវានុវត្តន៍ និងអ្នកសម្របសម្រួលមូលដ្ឋាន៖*** *ដើម្បីជំរុញការអនុវត្តទីក្រុងឆ្លាតវៃ ប្រកប ដោយនិរន្តរភាព និងបរិយាបន្ន នៅក្រុងព្រះសីហនុ ឱ្យបានល្អប្រសើរ វាជាការចាំបាច់ដែលត្រូវបង្កើត "អង្គភាពនវានុវត្តន៍" នៅក្នុងក្រុង ដែលមានបុគ្គលិកច្បាស់លាស់ដើម្បីអនុវត្តតាមដំណើរការផ្លាស់ប្តូរទៅកាន់ឌីជីថល។ "អង្គភាពនវានុវត្តន៍" នឹងគ្រប់គ្រងសេវាកម្មតាមអ៊ីនធើណិតឆ្លើយតបទៅនឹងសំណូមពររបស់ប្រជាពលរដ្ឋ និងសម្របសម្រួលការងារដល់អ្នកសម្របសម្រួលមូលដ្ឋាន និងទូតទីក្រុងឆ្លាតវៃដែលធ្វើការនៅកម្រិតសហគមន៍។*

៣. ***កិច្ចសហការអចិន្ត្រៃយ៍ជាមួយស្ថាប័នសិក្សាធិការ និងមជ្ឈមណ្ឌលអប់រំ៖*** *កិច្ចសហការជាមួយប្រព័ន្ធអប់រំគឺជាសកម្មភាពយុទ្ធសាស្ត្រ ដើម្បីជំរុញកម្មវិធីទីក្រុងឆ្លាតវៃប្រកបដោយផ្លែផ្កានៅថ្នាក់ក្រុង និងខេត្ត។ ស្ថាប័នសិក្សាធិការ គួរដាក់បញ្ចូលតាំងពីថ្នាក់កម្រិតដំបូងអំពីកសាងសមត្ថភាពទីក្រុងឆ្លាតវៃ ដើម្បីរចនាការអប់រំឌីជីថលកម្រិតខ្ពស់ឱ្យបានគ្រប់គ្រាន់ និងអចិន្ត្រៃយ៍ ព្រមទាំងធានាថាអ្នកជំនាញ វ័យក្មេង/ជំនាន់ថ្មីនឹងទទួលបានអត្ថប្រយោជន៍ពីការផ្លាស់ប្តូរទៅកាន់ឌីជីថល។*

៤. ***ក្រុមភាពជាដៃគូអចិន្ត្រៃយ៍ជាមួយភាគីពាក់ព័ន្ធ៖*** *ក្របខ័ណ្ឌទីក្រុងឆ្លាតវៃ ត្រូវបានដាក់ឱ្យដំណើរការដោយស្ថាប័នសាធារណៈ ប៉ុន្តែវាត្រូវតែអនុវត្តដោយមានការគាំទ្រពីភាគីពាក់ព័ន្ធសំខាន់ៗ របស់ក្រុង ព្រះសីហនុផងដែរ។ ការបង្កើតភាពជាដៃគូអចិន្ត្រៃយ៍ជាមួយភាគីពាក់ព័ន្ធនានា នឹងគាំទ្រដល់ការ អនុវត្តយុទ្ធសាស្ត្រទីក្រុងឆ្លាតវៃ ព្រមទាំងពង្រឹងអំណាចសេដ្ឋកិច្ចក្នុងស្រុក។*

៥. ***យុទ្ធនាការទំនាក់ទំនង/ផ្សព្វផ្សាយ៖*** *ចាំបាច់ត្រូវតែរៀបចំយុទ្ធនាការទំនាក់ទំនង/ផ្សព្វផ្សាយ ដើម្បីជំរុញឱ្យមានការប្រើប្រាស់ឧបករណ៍ឌីជីថល សម្រាប់អភិបាលកិច្ចអេឡិចត្រូនិក និងទាក់ទាញការចូលរួមពីប្រជាពលរដ្ឋ ទាំងនៅក្នុងតំបន់ជនបទ និងទីក្រុងព្រមទាំងការផ្សាយ ពាណិជ្ជកម្ម ការផ្សាយតាមវិទ្យុ និងសកម្មភាពសមស្របផ្សេងៗទៀត ដើម្បីផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋ អំពីសារៈសំខាន់នៃ ការប្រើប្រាស់បច្ចេកវិទ្យា និងប្រព័ន្ធ ICT ជាឧបករណ៍លើកកម្ពស់បរិយាបន្ន ប្រជាធិបតេយ្យ និងនិរន្តរភាព។*

១. **ការកសាងសមត្ថភាពសម្រាប់បុគ្គលិកស្ថាប័នសាធារណៈ**
អំពីការធ្វើឌីជីថលនីយកម្ម ចំណេះដឹងកុំព្យូទ័រ

២. **ក្រុមភាពជាដៃគូរអចិន្ត្រៃយ៍ជាមួយភាគីពាក់ព័ន្ធ**
ភាពជាដៃគូអចិន្ត្រៃយ៍ជាមួយភាគីពាក់ព័ន្ធនានា នឹងគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រទីក្រុងឆ្លាតវៃ ព្រមទាំងពង្រឹងអំណាចសេដ្ឋកិច្ចក្នុងស្រុក

៣. **អំពីការធ្វើឌីជីថលនីយកម្ម ចំណេះដឹងកុំព្យូទ័រ**
ដើម្បីគ្រប់គ្រងសេវាកម្មតាមអ៊ីនធើណិត/ឆ្លើយតបទៅនឹងសំណូមពររបស់ប្រជាពលរដ្ឋ
**អ្នកសម្របសម្រួលមូលដ្ឋាន**
ដើម្បីសម្របសម្រួលការងារជាមួយទូតទីក្រុងឌីជីថលនៅកម្រិតសហគមន៍

៤. **យុទ្ធនាការទំនាក់ទំនង**
ដើម្បីជំរុញឱ្យមានការប្រើប្រាស់ឧបករណ៍ឌីជីថលសម្រាប់អភិបាលកិច្ចអេឡិចត្រូនិក និងទាក់ទាញការចូលរួមពីប្រជាពលរដ្ឋ

៥. **កិច្ចសហការអចិន្ត្រៃយ៍**
ជាមួយស្ថាប័នសិក្សាធិការ និងមជ្ឈមណ្ឌលអប់រំ

៦. **ការធ្វើតេស្ត និងការត្រួតពិនិត្យសកម្មភាពឆ្លាតវៃសាកល្បង**
គំនិតផ្តួចផ្តើម ១.១, ១.២, ១.៣, ២.១, ៣.១, ៣.១

៧. **ការធ្វើបច្ចុប្បន្នភាពទិន្នន័យ**
ទិន្នន័យថ្មីៗគឺជាធាតុចូលសម្រាប់ធ្វើបច្ចុប្បន្នភាពដំណើរការនៃការអនុវត្ត

៦. ***ការធ្វើតេស្ត និងការត្រួតពិនិត្យសកម្មភាពឆ្លាតវៃសាកល្បង៖*** *វាមានសារៈសំខាន់ណាស់ក្នុងការផ្តល់ឱកាសឱ្យប្រជាជនធ្វើការពិសោធន៍ដោយផ្ទាល់នូវសក្តានុពលនៃឧបករណ៍បរិយាបន្នឆ្លាតវៃ។ ដោយហេតុផលនេះ ការចាប់ផ្តើមអនុវត្តសាកល្បងនូវគំនិតផ្តួចផ្តើមនៃទស្សនទានទីក្រុងឆ្លាតវៃ ប្រកប ដោយនិរន្តរភាព និងបរិយាបន្ន គួរត្រូវបានបង្កើតឡើង។ ដំណើរការវាយតម្លៃ មួយគួរតែត្រូវបានបង្កើតឡើង ដើម្បីត្រួតពិនិត្យលទ្ធផលនៃសកម្មភាពសាកល្បង និងដើម្បីកំណត់រកវិធីសាស្ត្រកែលម្អ។*

យោងតាមបរិបទមូលដ្ឋាននិងអាទិភាពដែលបានបង្ហាញដោយក្រុមការងារក្នុងមូលដ្ឋាន គំនិតផ្តួច ផ្តើមទីក្រុងឆ្លាតវៃខាងក្រោមនេះ គួរត្រូវបានជ្រើសរើសជាគំនិតផ្តួចផ្តើមឆ្លាតវៃដំបូងគេ សម្រាប់អនុវត្តសាកល្បងនៅក្រុងព្រះសីហនុ៖

## សសរស្តម្ភ ទី១

- ***គំនិតផ្តួចផ្តើម ១.១.*** *វេទិកាឆ្លាតវៃ សម្រាប់ក្រុងព្រះសីហនុ តាមរយៈការចូលរួមអេឡិចត្រូនិក*
- ***គំនិតផ្តួចផ្តើម ១.២.*** *វេទិកាអភិបាលកិច្ចអេឡិចត្រូនិក សម្រាប់ប្រជាពលរដ្ឋ*
- ***គំនិតផ្តួចផ្តើម ១.៣.*** *មជ្ឈមណ្ឌលសហគមន៍ឆ្លាតវៃ*

គំនិតផ្តួចផ្តើមឆ្លាតវៃ ខាងលើ អាចឱ្យមានការចែករំលែកព័ត៌មាន និងទិន្នន័យ ដើម្បីគាំទ្រដល់អភិបាលកិច្ចមូលដ្ឋាន និងលទ្ធិប្រជាធិបតេយ្យ (១.២) ជំរុញឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋកាន់តែសកម្មក្នុងការសម្រេចចិត្តទាក់ទងនឹងការអភិវឌ្ឍមូលដ្ឋាន (១.១) និងការចូលរួមរបស់សហគមន៍ (១.៣)។

តាមរយៈគំនិតផ្តួចផ្តើម ១.១ ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាននឹងមានលទ្ធភាព ប្រាប់ពីតម្រូវការ និងបំណងប្រាថ្នារបស់ពួកគេ ដើម្បីយកមកអនុវត្តក្នុងគំនិតផ្តួចផ្តើមនៃសសរស្តម្ភទី២ ដែលផ្តោតលើឱកាស ដើម្បីរៀបចំឡើងវិញនូវសេវាកម្មសាធារណៈ និងបរិក្ខារអភិវឌ្ឍទីក្រុង (ដូចជាការគ្រប់គ្រងសំណល់ ការធ្វើ ដំណើរការកាន់កាប់ដីធ្លី និងលំនៅឋាន សុខភាព សុវត្ថិភាព ... ជាដើម។ ល។) តាមរយៈការចូលរួមរបស់ ប្រជាពលរដ្ឋដោយសកម្មភាពឆ្លាតវៃ និងផ្អែកលើព័ត៌មានដែលមានប្រភពពីមហាជន។ គំនិតផ្តួចផ្តើម ១.៣ នឹងជំរុញការផ្លាស់ប្តូរទៅកាន់ឌីជីថលនៅកម្រិតសហគមន៍ ដោយគាំទ្រឱ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានបង្ហាញពីបញ្ហា និងចូលរួមរកដំណោះស្រាយរួមគ្នាក្រោមគំនិតផ្តួចផ្តើម១.១ និងសម្រេចតាមរយៈគំនិតផ្តួចផ្តើមនៃ សសរស្តម្ភទី២ ។

## សសរស្តម្ភ ទី២

- ***គំនិតផ្តួចផ្តើម ២.១. ៖ ផែនទីបរិស្ថាន (ការគ្រប់គ្រងសំណល់, ទឹកជំនន់...) តាមរយៈព័ត៌មាន ដែលមានប្រភពពីមហាជនតាមប្រព័ន្ធឌីជីថល***

គំនិតផ្តួចផ្តើម ២.១ គឺជាសកម្មភាពអាទិភាពសម្រាប់ក្រុងព្រះសីហនុ ដោយគិតគូរពីបញ្ហាដែលកំពុង កើតមានទាក់ទងនឹងសំណល់ ការបំពុលបរិស្ថាន និងទឹកជំនន់។ គំនិតផ្តួចផ្តើមនេះ គួរតែជាសកម្មភាពសាកល្បង សម្រាប់វិភាគពីលទ្ធភាពក្នុងការរួមគ្នាបង្កើតដំណោះស្រាយ ការផ្តល់សេវាកម្ម និងការបង្កើតមធ្យោបាយថ្មីៗ តាមរយៈការចូលរួមដោយផ្ទាល់ពីប្រជាជនក្នុងមូលដ្ឋាន ដើម្បីជាការឆ្លើយតបជាក់ស្តែងចំពោះបញ្ហាបរិស្ថាន។

តាមរយៈសកម្មភាពនេះ សហគមន៍ នឹងចូលរួមយ៉ាងសកម្មក្នុងការសន្ទនាថ្មីមួយ ជាមួយអាជ្ញាធរមូលដ្ឋាន និងនៅក្នុងប្រព័ន្ធគ្រប់គ្រងបរិស្ថានប្រកបដោយការទទួលខុសត្រូវរួមគ្នា។

ការអនុវត្តសាកល្បងនូវឧបករណ៍ឌីជីថល និងការត្រួតពិនិត្យ តាមរយៈមជ្ឈមណ្ឌលសហគមន៍ឆ្លាតវៃ (១.៣) នឹងត្រូវធ្វើឡើងក្នុងសហគមន៍មូលដ្ឋាន ដែលត្រូវបានជ្រើសរើស ។

## សសរស្តម្ភ ទី៣

- ***គំនិតផ្តួចផ្តើម ៣.១. តំបន់សេវាអ៊ីនធើណិតឥតគិតថ្លៃក្នុងទីក្រុង និងជាយក្រុង ជាពិសេសសម្រាប់ប្រជាជនក្រីក្រ និងក្រុមដែលមិនមានឱកាសទទួលបានសេវាកម្មអ៊ីនធើណិត***
- ***គំនិតផ្តួចផ្តើម ៣.២. ៖ កម្មវិធីបណ្តុះបណ្តាលកុំព្យូទ័រ និងបច្ចេកវិទ្យាអចិន្ត្រៃយ៍ សម្រាប់ប្រជាពលរដ្ឋ ជាពិសេសយុវជន តាមរយៈការបង្កើត «ទូតទីក្រុងឌីជីថល»***

គំនិតផ្តួចផ្តើមទាំងពីរនេះអនុញ្ញាតឱ្យក្រុងព្រះសីហនុដោះស្រាយបញ្ហាគម្លាតឌីជីថល និងផ្តល់នូវកម្មវិធីអប់រំមួយដល់ប្រជាពលរដ្ឋ ដែលត្រូវបានបញ្ចូលក្នុងដំណើរការផ្លាស់ប្តូរទៅកាន់ឌីជីថល តាមរយៈវិធីសាស្រ្តបរិយាបន្ន។

*៧. **ការធ្វើបច្ចុប្បន្នភាពទិន្នន័យ៖** ប្រព័ន្ធទីក្រុងឆ្លាតវៃនឹងបង្កើតនូវទិន្នន័យជាច្រើនដែលត្រូវប្រើប្រាស់ ដើម្បីធ្វើបច្ចុប្បន្នភាពទស្សនទាន និងគំនិតផ្តួចផ្តើមឆ្លាតវៃ។ ការអភិវឌ្ឍទីក្រុងឆ្លាតវៃ ត្រូវតែមាននូវទិន្នន័យថ្មីៗជាបន្តបន្ទាប់ ដើម្បីជាធាតុចូលសម្រាប់ធ្វើបច្ចុប្បន្នភាពដំណើរការនៃការអនុវត្ត។*

## LAUNCHING THE FIRST SMART INITIATIVES



# ៦. សន្និដ្ឋាន និងអនុសាសន៍

គម្រោងនេះ  បានចង្អុលបង្ហាញពីសារៈសំខាន់ដែលការអភិវឌ្ឍន៍ទីក្រុងឆ្លាតវៃសម្រាប់ក្រុងព្រះសីហនុចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់ចំពោះតម្រូវការរបស់ប្រជាជនគ្រប់រូប ជាពិសេសគឺក្រុមដែលងាយរងគ្រោះ តាមរយៈវិធីសាស្ត្រសន្តិសុខមនុស្សជាតិ។

ទស្សនទានទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្នសម្រាប់ក្រុងព្រះសីហនុ ត្រូវបានចងក្រងដោយមានសសរស្តម្ភចំនួន៣ និងគំនិតផ្តួចផ្តើមឆ្លាតវៃចំនួន ១៣ ដោយយកទស្សនៈ «មិនមានពលរដ្ឋណាម្នាក់ត្រូវបានគេទុកចោល» ជាស្នូល។ ទស្សនៈទានទីក្រុងឆ្លាតវៃនេះ ផ្អែកទៅលើគោលការណ៍សំខាន់ៗចំនួន៣  គឺ៖ វិធីសាស្ត្រទីក្រុងឆ្លាតវៃដែលផ្តោតលើប្រជាពលរដ្ឋ  ទស្សនទានសិទ្ធិមនុស្សសម្រាប់ទីក្រុងឆ្លាតវៃ  និងការផ្តោតសំខាន់លើ  ក្មេងស្រី និងស្ត្រីសម្រាប់ទីក្រុងឆ្លាតវៃ។

គំនិតផ្តួចផ្តើមឆ្លាតវៃត្រូវបានរៀបចំឡើងជាពីរកម្រិត គឺ កម្រិតក្រុង និងកម្រិតសហគមន៍៖

- ***គំនិតផ្តួចផ្តើមឆ្លាតវៃនៅកម្រិតក្រុង***

  គំនិតផ្តួចផ្តើមឆ្លាតវៃនៅកម្រិតក្រុងមានទិសដៅជំរុញប្រសិទ្ធភាពអភិបាលកិច្ចក្នុងក្រុងព្រះសីហនុ។ គោលបំណងសំខាន់នៃគំនិតផ្តួចផ្តើមនេះ គឺដើម្បីបង្កឱ្យមានការចូលរួមរបស់ប្រជាជនក្នុងដំណើរការធ្វើការសម្រេចចិត្តតាមរយៈវេទិកាសម្រាប់ការចូលរួមអេឡិចត្រូនិច (គំនិតផ្តួចផ្តើម ១.១) ការបង្កើតច្រកទំនាក់ទំនងរវាងប្រជាពលរដ្ឋនិងអាជ្ញាធរមូលដ្ឋាន  ដោយប្រើប្រាស់វេទិការអភិបាលកិច្ចអេឡិចត្រូនិច (ផ្តួចផ្តើម ១.២) និងការផ្តល់សេវាកម្មឆ្លាតវៃប្រកបដោយភាពច្នៃប្រឌិតដោយផ្អែកលើគំនិផ្តួចផ្តើមនៃសសរស្តម្ភទី ២ និងទី ៣។

- ***គំនិតផ្តួចផ្តើមឆ្លាតវៃនៅកម្រិតសហគមន៍***

  គំនិតផ្តួចផ្តើមឆ្លាតវៃនៅកម្រិតសហគមន៍ មានទិសដៅដាក់បញ្ចូលសហគមន៍មូលដ្ឋាន  ទៅក្នុងដំណើរការផ្លាស់ប្តូរទៅរកឌីជីថល ដើម្បីធានាថាពួកគាត់នឹងទទួលបានអត្ថប្រយោជន៍គ្រប់ជ្រុងជ្រោយពីការផ្លាស់ប្តូរនេះ។ ការដាក់បញ្ចូលក្រុមប្រជាពលរដ្ឋដែលខ្វះឱកាស ស្ត្រី និងក្មេងស្រីទៅក្នុងយុទ្ធសាស្ត្រឆ្លាតវៃ  និងការផ្តល់នូវគំនិតផ្តួចផ្តើមឆ្លាតវៃនៅកម្រិតសហគមន៍ គឺជាមូលដ្ឋានគ្រឹះនៃទស្សនទានទីក្រុងឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ននេះ។ ការអនុវត្តន៍ការងារនានា នៅក្នុងកម្រិតសហគមន៍ ត្រូវបានព្យាករណ៍ថាចាំបាច់ត្រូវមានការចូលរួមដោយផ្ទាល់របស់ប្រជាពលរដ្ឋក្នុងសហគមន៍តាមរយៈមជ្ឈមណ្ឌលសហគមន៍ឆ្លាតវៃ និងកម្មវិធីថែទាំសុខភាពសហគមន៍។ ទីកន្លែងសម្រាប់ការជួបជុំដោយផ្ទាល់  និងលំហនិម្មិត  សម្រាប់តែស្ត្រី  និងក្មេងស្រីចាំបាច់ត្រូវតែបានបង្កើតឡើង  ដើម្បីឲ្យពួកគេមានឱកាសក្នុងការបង្ហាញពីគំនិត  តម្រូវការ  និងសេចក្តីប្រាថ្នារបស់ពួកគេ។ រាល់ព័ត៌មាន និងការយល់ឃើញរបស់សហគមន៍អំពីបញ្ហាការដឹកជញ្ជូន   សុខភាព សុវត្ថិភាព  បញ្ហាសំណល់  ទឹក  និងទឹកជំនន់ជាដើម នឹងត្រូវបានចែករំលែកជាមួយប្រជាពលរដ្ឋដ៏ទៃទៀតក្នុងទីក្រុងទាំងមូលតាមរយៈ  វេទិកាឆ្លាតវៃសម្រាប់ក្រុងព្រះសីហនុ តាមរយៈការចូលរួមអេឡិចត្រូនិក (គំនិតផ្តួចផ្តើម ១.១)។ តាមរយៈវិធីសាស្ត្រនេះ រាល់សំណើ គំនិត បញ្ហា និងបំណងប្រាថ្នានានា នឹងត្រូវបានលើកយកមកពិចារណារដើម្បីរកដំណោះស្រាយរួមសម្រាប់សហគមន៍ទាំងមូល។

លក្ខណៈច្នៃប្រឌិតនៃយន្តការឆ្លាតវៃនេះ  គឺភាពស៊ីគ្នារវាងសេវាកម្មសហគមន៍  និងការធ្វើអភិបាលកិច្ចទីក្រុងដែលនឹងត្រូវអនុវត្តន៍ តាមរយៈវេទិការអនឡាញ (online) និងការជួបជុំដោយផ្ទាល់ ដែលចាំបាច់ត្រូវមានការសម្រប

សម្រួលពីមន្ត្រីបង្គោលជាក់លាក់ នឹងការចូលរួមពីភាគីពាក់ព័ន្ធទាំងនៅកម្រិតទីក្រុង និងសហគមន៍។

- ***មន្ត្រីបង្គោល និងអ្នកពាក់ព័ន្ធនៅកម្រិតទីក្រុង***

  ក្រុងព្រះសីហនុចាំបាច់គួរតែបង្កើតនូវ “អង្គភាពនវានុវត្តន៍” នៅក្នុងក្រុងដែលមានបុគ្គលិកច្បាស់លាស់ដើម្បីសម្របសម្រួល និងដឹកនាំដំណើរការអភិវឌ្ឍទីក្រុងឆ្លាតវៃ។ “អង្គភាពនវានុវត្តន៍” នេះនឹងគ្រប់គ្រងសេវាកម្មតាមអ៊ីនធើណិត ឆ្លើយតបទៅនឹងសំណូមពររបស់ប្រជាពលរដ្ឋ និងសម្របសម្រួលការងារដល់អ្នកសម្របសម្រួលមូលដ្ឋាន និងទូតទីក្រុងឌីជីថល ដែលធ្វើការនៅកម្រិតសហគមន៍។ បន្ថែមលើនេះ អង្គភាពនវានុវត្តន៍ នឹងសហការជាមួយ «ក្រុមភាពជាដៃគូអចិន្ត្រៃយ៍សម្រាប់ទីក្រុងឆ្លាតវៃ» ដែលរួមមានភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងក្រុងព្រះសីហនុ ដែលគាំទ្រដល់ការអនុវត្តទីក្រុងឆ្លាតវៃ និងមានឥទ្ធិពលលើកំណើនសេដ្ឋកិច្ច ក៏ដូចជាស្ថាប័នអប់រំដែលមានតួនាទីជម្រុញ កម្មវិធីអប់រំឌីជីថលអចិន្ត្រៃយ៍ផងដែរ។

- ***មន្ត្រីបង្គោល និងអ្នកពាក់ព័ន្ធនៅកម្រិតសហគមន៍***

  អ្នកសម្របសម្រួលមូលដ្ឋានមានតួនាទីទទួលខុសត្រូវចំពោះការអនុវត្តគំនិតផ្តួចផ្តើមឆ្លាតវៃ នៅកម្រិតសហគមន៍ តាមរយៈមជ្ឈមណ្ឌលសហគមន៍ឆ្លាតវៃ (គំនិតផ្តួចផ្តើម ១.៤)។ សហគមន៍មូលដ្ឋាននឹងត្រូវបានជម្រុញឲ្យចូលរួមក្នុងការអនុវត្តគំនិតផ្តួចផ្តើមទាំង១៣ ដើម្បីសហការកំណត់ពីសេវាកម្ម និងគ្រឿងបរិក្ខារនានា ដែលជាតម្រូវរបស់សហគមន៍។ បន្ថែមលើនេះ ទូតទីក្រុងឌីជីថលនឹងត្រូវបានបង្កើតឡើងដើម្បីជំរុញការអនុវត្តកម្មវិធីទីក្រុងឆ្លាតវៃអន្តរជំនាន់ និងដើម្បីលើកកម្ពស់ចំណេះ ដឹងឌីជីថលនៅកម្រិតសហគមន៍។ ទូតទីក្រុងឌីជីថលដែលត្រូវបានជ្រើសរើសនឹងត្រូវបានបណ្តុះបណ្តាលអំពីឧបករណ៍ឌីជីថលដែលប្រើប្រាស់ជាសកលនៅក្នុងទីក្រុងឆ្លាតវៃ ព្រមទាំងគំនិតផ្តួចផ្តើមទាំង១៣ នៃទស្សនទានទីក្រុងឆ្លាតវៃនេះផងដែរ។ អ្នកសម្របសម្រួលសហគមន៍ និងទូតទីក្រុងឌីជីថល នឹងត្រូវបានសម្របសម្រួលដោយអង្គភាពនវានុវត្តន៍។ ពួកគេនឹងដើរតួរយ៉ាងសំខាន់ក្នុងការអនុវត្តគំនិតផ្តួចផ្តើមឆ្លាតវៃនៅកម្រិតសហគមន៍ ជាពិសេសគឺដើម្បីគាំទ្រដល់ក្រុមជនងាយរងគ្រោះ ដែលជាស្នូលនៃទស្សនទានឆ្លាតវៃ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន។

## វិធីសាស្ត្រនៃសសរស្តម្ភទាំង៣ និងគំនិតផ្តួចផ្តើមទាំង១៣



**គំនិតផ្តួចផ្តើមឆ្លាតវៃនៅថ្នាក់ក្រុង**

តាមរយៈអភិបាលកិច្ចអេឡិចត្រូនិច,
ការចូលរួមអេឡិចត្រូនិច, សេវាកម្មឆ្លាតវៃ

គាំទ្រដោយ

*អង្គភាពនវានុវត្តន៍ ស្ថាប័នអប់រំ
និងភាពជាដៃគូទីក្រុងឆ្លាតវៃ*

**គំនិតផ្តួចផ្តើមឆ្លាវៃនៅថ្នាក់មូលដ្ឋាន**

តាមរយៈមជ្ឈមណ្ឌលសហគមន៍ឆ្លាតវៃ,
ការថែទាំសុខភាពសហគមន៍

គាំទ្រដោយ

*អ្នកសម្របសម្រួលសហគមន៍
និងទូតទីក្រុងឌីជីថល*